ព្រះ
ត្រៃបិដកបាលី
និង
សេចក្តីប្រែជាភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ អបទាន
ចតុត្ថភាគ
៧៥

ពោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព.ស ២៥០៦

ឯកសារគម្ពីព្រះត្រៃបិដកស្កានេះ
ត្រូវបានថតចេញពី ច្បាប់គម្ពីរព្រះត្រៃបិដកជប៉ុន ។

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ ៥១ ដល់ ភាគ ១១០
ត្រូវបានរៀបចំធ្វើឡើងដោយ គេហទំព័រ ៥000ឆ្នាំ ប្ជូជា
ចំពោះព្រះពុទ្ធសាសនា សម្រាប់ជាធម្មទាន ។

ផ្តល់សៀវភៅគម្ពីរព្រះត្រៃបិដកសម្រាប់ការងារ
ដោយ ឧបាសិកា កាំង ហ្ជិចណែ ។

គ្រប់គ្រងគម្រោង (ទូទៅ និងផ្នែកបច្ចេកទេស)
ដោយ ឧបាសក ស្រុង-ចាន់ណា ។

ត្រួតពិនិត្យឡើងវិញ
ដោយ ចន-ស្រីស្រស់ ។

ថតស្កានដោយ
ភ្ជួនប្រុស ម៉ាន់ សាវ៉ាត

www.5000-years.org

ក្រោមការឧបត្ថម្ភយ៉ាងច្រើនលើសអំពីៈ

- ឧបាសិកា កាំង ហ្គិចណែ (ភ្នំពេញ)
- ឧបាសក ដុត លីស្រុង និង ឧបាសិកា លី សុខា ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក សន ចន និង ឧបាសិកា អ៊ូច សាវ៉ៃង ព្រមទាំងបុត្រ (បាត់ដំបង)
- ឧបាសក ជា ស៊ីវន្ធានា និងឧបាសិកា ឃុន សូនីម៉ា ព្រមទាំងបុត្រី ជា សុមេធាធីតា (ស.រ.អ)
- លោក ជីម-ជា និងលោកស្រី រតនំ ស្រីមុំ (ភ្នំពេញ)
- ឧបាសក ជ្រ ផែង យ៉ៃន (ហ្ស្ការ)
- លោក ស៊ីក ចាន់សេរ៉ី (បន្ទាយមានជ័យ)
- ឧបាសិកា យ៉ា វ៉ាន់ី (បន្ទាយមានជ័យ)
- ប្អូនស្រី យ៉ា សុភ: (បន្ទាយមានជ័យ)
- ឧបាសិកា កោ សេង (ភ្នំពេញ)
- លោកស្រី ប៉ាន សុគន្ធានីន និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- ឧបាសក ស្រុង ចាន់ណា និង ឧបាសិកា ចន ស្រីស្រស់
  ព្រមទាំងបុត្រ ចាន់ណា សុធានធីរាជ, ចាន់ណា សុធានធិវ៉ាធ (ភ្នំពេញ)
- លោកស្រី ស្រុង ចាន់ឌីស្ម៉ី និង ស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- កញ្ញា ស្រុង ចាន់ឌីតនា (ភ្នំពេញ)
- លោក ស្រុង យូហេង (ភ្នំពេញ)
- លោក ឆង សុផល (ហ្ស្ការ)
- ប្អូនស្រី សុខ អេង (កំពង់ចាម)
- កញ្ញា ចន កក្កដា (បាត់ដំបង)
- លោកស្រី ចន សត្យា និងលោក ទ្ធត សេរីសុ៊ីក ព្រមទាំងបុត្រ (ភ្នំពេញ)
- លោក ចន រ៉ាចនា (បាត់ដំបង)
- កញ្ញា ស៊ីស សុផានី (បាត់ដំបង)
- កញ្ញា យ៉ៃម សុផានី (បាត់ដំបង)
- លោក ម៉ៅ គន្ធា និងលោកស្រី ផ្យ៉ង សេដ្ឋា (បាត់ដំបង)
- លោក សៅ សារ៉ុម (បាត់ដំបង)
- ព្រះតេជព្រះគុណ ជ្ជ សារ: (ព្រះចៅអធិការវត្ត សម សាន្ត ខេត្តបាត់ដំបង)
- ឧបាសិកា ង៉ាន់ លុយ និងស្វាមី ព្រមទាំងបុត្រ (ភ្នំពេញ)
- លោកស្រី ហ្ជ ច័ន្ទសុវណ្ណ និងស្វាមី ព្រមទាំងបុត្រ (ស.រ.អ)

ព្រះ
ត្រៃបិដកបាលី
និង
សេចក្ដីប្រៀបធៀបភាសាខ្មែរ
សុត្តន្តបិដក
ខុទ្ទកនិកាយ ទសកនិបាត
ចតុត្ថភាគ
៧៥



បោះពុម្ពលើកទី ១

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

ព. ស. ២៥០៦

ឧទ្ទិសកថា

យើងខ្ញុំ សូមផ្តល់ស្ការតីសូត្រព្រះធម៌ឧទ្ទិសជូនជនជាតិខ្មែរ ។
ឥឡូវ យើងខ្ញុំអាចជូនគម្ពីរព្រះត្រៃបិដកនេះ ទៅអ្នកកាន់ព្រះពុទ្ធសាសនាជនជាតិខ្មែរបានហើយ ។
ព្រះធម៌នៃព្រះពុទ្ធជាម្ចាស់នេះ ត្រូវបានសូត្រចេញពីជម្រៅដួងចិត្តនៃអ្នកកាន់ព្រះពុទ្ធសាសនា
ជនជាតិជប៉ុន ។

このカンボジア版南伝大蔵経を
カンボジアの佛教徒へ
贈ることができることに感謝します。
これが日本の佛教徒の心です。

It is with a deep sense of gratitude that I present the translation of the complete TRIPITAKA to Cambodian Buddhists on behalf of the Japanese Buddhist community.

អារម្ភកថា

ជូនចំពោះជនជាតិខ្មែរ ជាទីរាប់អាន !

ជូនចំពោះជនជាតិខ្មែរដែលកាន់ព្រះពុទ្ធសាសនា ជាទីគោរព !

គម្ពីរព្រះត្រៃបិដកខ្មែរនេះ ត្រូវបាន" ក្រុមជំនុំព្រះត្រៃបិដក" នៃពុទ្ធសាសនបណ្ឌិត្យ នៅភ្នំពេញ បកប្រែពីភាសាបាលីមកជាភាសាខ្មែរ តាំងពីឆ្នាំ ១៩៣០ ទៅឆ្នាំ ១៩៦៨ គឺត្រូវចំណាយពេល ៣៩ ឆ្នាំ ទើបបានសម្រេចហើយសព្វគ្រប់ ។ នេះពិតជាកំណប់ព្រះធម៌របស់ព្រះពុទ្ធសាសនាខ្មែរ ហើយក៏ជាកំណប់វប្បធម៌ខាងផ្នែកបោះពុម្ពរបស់ជនជាតិខ្មែរផងដែរ ។ យើងខ្ញុំ ពុទ្ធសាសនិកជាតិជប៉ុន មានសន្ធានចិត្តរីករាយនឹងបោះពុម្ពជាថ្មីឡើងវិញ ដោយសង្ឃឹមថា ព្រះពុទ្ធសាសនាខ្មែរក៏នឹងរុងរឿងឡើងវិញដែរ ។

នេះគឺជាអំណោយពីជម្រៅដួងចិត្ត ជូនទៅដល់ជនជាតិខ្មែរទាំងអស់ ព្រមទាំងមនុស្សជាតិទូទៅ នៅក្នុងពិភពលោកនេះ ដែលមានចិត្តស្រឡាញ់សន្តិភាព ។

ខ្មែរបានរងសោកនាដកម្មដែលមិនធ្លាប់មានពីមុនមក ។ ម្យ៉ាងទៀត ព្រះពុទ្ធសាសនាខ្មែរ ក៏ត្រូវអន្តរាយយ៉ាងខ្លាំង ក៏ប៉ុន្តែឥឡូវនេះ យើងទាំងអស់គ្នា បានឈានជើងកន្លងផុតពីសេចក្ដីទុក្ខសោកដ៏ធ្ងន់ធ្ងរនេះ ចាកផុតពីអំពើហោរហៅ បញ្ចប់គំនុំគុំគួន ដើរតាមពុទ្ធដីកាព្រះបរមគ្រូ ខិតខំព្យាយាមធ្វើឲ្យមានសន្តិភាពក្នុងពិភពលោក ។

ការណ៍ដែលយើងខ្ញុំជូនគម្ពីរព្រះត្រៃបិដកពេលនេះ គឺជានិមិត្តរូបនៃការប្ដេជ្ញាចិត្តរបស់អ្នកកាន់ព្រះពុទ្ធសាសនាជនជាតិជប៉ុនថា យើងខ្ញុំធ្វើសហប្រតិបត្តិការដើម្បីសន្តិភាពក្នុងពិភពលោក ដើម្បីទុកជាភស្តុតាងនៃចំណងមេត្រីភាព និងមិត្តភាពរវាងប្រជាជាតិជប៉ុន និងប្រជាជាតិខ្មែរ ។

ថ្ងៃនក្ষត្ត្ឫក្ষ កក្កដា ឆ្នាំ ១៩៩៤

សមាគមជំនួយដល់ការបោះពុម្ពព្រះត្រៃបិដកឡើងវិញ

អ្នកតំណាងចាត់ការ The Rev. Seikyo Muchaku

ប្រធានការិយាល័យ The Rev. Eiitsu Shinohara

អ្នកចាត់ការ

The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

『トリピタカ』復刻進呈にあたって

親愛なるカンボジアの皆さん！
敬愛するカンボジアの仏教徒の皆さん！

カンボジア版『トリピタカ』は、プノンペンの仏教研究所が、仏教界の英知を集め、1930年から1968年まで、39年の歳月をかけて翻訳し、分類し、集大成して完成されました。まさにカンボジア仏教の法宝であると共に、カンボジア出版文化の至宝です。日本仏教徒の有志は、カンボジア仏教の復興再生を願いつつ、これを復刻刊行し、贈らせていただきます。

これはカンボジア仏教徒のみならず、カンボジア全人民、否、平和を愛する地球上のすべての人々への、心からの贈り物です。

カンボジアは、古今未曾有の悲劇を体験しました。カンボジア仏教もこの受難の時代に壊滅的な打撃を受けました。しかし、今はその悲しみを乗りこえ、瞋りを離れ、怨みを怨し、ブッダの教えに従い、世界平和の実現に努力するときです。

この本の贈呈は、日本の仏教徒も共々に、世界平和のために努力することを誓うしるしであり、相互の連帯と友情の証なのです。

合掌

1994年７月吉日

カンボジア版トリピタカ（南伝大蔵経）復刻救援委員会

世話人代表　無着　成恭
事務局長　篠原　鋭一

世話人　松永　然道　有馬　実成
伊藤　佳通　渡井　奎一
杉谷　義純　茂田　真澄
前田　利勝　中島　教之
永　六輔

Acknowledgment

Dear Cambodian friends and respected members of the Cambodian Buddhist community,

It is a matter of great joy that the translation into Cambodian of the Pali Tripitaka has been completed and published. The Tripitaka Commisson of the Buddhist Institute, Phnom Penh, launched the translation project in 1930 and completed the translation, after 39 years of effort, in 1968.

The Cambodian translation of this great work will not only become a cherished treasure of the Cambodian Buddhist community but will also be an important milestone in the history of publication in Cambodia.

The revival and prosperity of Buddhism in Cambodia are the ardent wish of the Japanese Buddhist community, it is in this spirit that we have completed this important project and now present the entire work to the Cambodian Buddhist community, it is a gift not only to the Buddhist community in Cambodia but also to all Cambodian people and all peace-loving people in the world.

Cambodia experienced great tragedies in modern times, and the Cambodian Buddhist community also underwent severe trials and suffered crushing blows during this period. But now a time has come to surmount grief and anger, to forgive, and to start working again for world peace.

This great work is a symbol of the Japanese Buddhist community's resolve to work with our Cambodian brothers and sisters toward world peace and is a testimony to the friendship between our people.

With hands joined in reverence.
July 1994

TRIPITAKA PUBLISHING SUPPORT COMMITTEE
Project Manager : The Rev. Seikyo Muchaku
Secretary General : The Rev. Eiitsu Shinohara
Management Team :
The Rev. Zendo Matsunaga The Rev. Jitsujo Arima The Rev. Yoshimichi Ito
The Rev. Keiichi Watai The Rev. Gijun Sugitani The Rev. Shincho Shigeta
The Rev. Risho Maeda The Rev. Kyoshi Nakajima Mr. Rokusuke Ei

សុត្តន្តបិដក

ខុទ្ទកនិកាយ អបទាន

ចតុត្ថភាគ

៧៥

ព.ស. ២៥០៦

សុត្តន្តបិដកេ

ខុទ្ទកនិកាយស្ស អបទានំ

ចតុត្ថោ ភាគោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ទ្វាចត្តាឡីសមោ ភទ្ទាលិវគ្គោ

បឋមំ ភទ្ទាលិត្ថេរាបទានំ

(១) សុមេធោ នាម សម្ពុទ្ធោ អគ្គោ ការុណិកោ មុនិ

វិវេកកាមោ លោកគ្គោ ហិមវន្តំ ឧបាគមិ ។

អជ្ឈោគហេត្វា ហិមវន្តំ(១) សុមេធោ លោកនាយកោ

បល្លង្កំ អាភុជិត្វាន និសីទិ បុរិសាសភោ(២) ។

សមាធឹ សោ សមាបន្នោ សុមេធោ លោកនាយកោ

សត្តរត្តិន្ទិវំ ពុទ្ធោ និសីទិ បុរិសុត្តមោ ។

ខារិកាជំ គហេត្វាន វនមជ្ឈោគហឹ អហំ

---

១ ឱ. ម. ហិមវំ ។ ២ ឱ. ម. បុរិសុត្តមោ ។

សុត្តន្តបិដក

ខុទ្ទកនិកាយ អបទាន

បត្តគ្គភាគ

សូមនមស្ការចំពោះព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

ភទ្ទាលិវគ្គ ទី ៤២

ភទ្ទាលិត្ថេរាបទាន ទី ១

(១) ព្រះសម្ពុទ្ធព្រះនាមសុមេធ: ជាបុគ្គលខ្ពង់ខ្ពស់ ប្រកបដោយសេចក្តីករុណា ជាអ្នកប្រាជ្ញ ប្រាជ្ញាសេចក្តីស្ងប់ស្ងាត់ ព្រះអង្គប្រសើរក្នុងលោក ទ្រង់ចានស្តេចចូលទៅ ក្នុងព្រៃហិមពាន្ត ។ ព្រះលោកនាយក ព្រះនាមសុមេធ: ជាបុរសដ៏ប្រសើរ លុះទ្រង់ស្តេចចូលទៅក្នុងព្រៃហិមពាន្តហើយ គង់ពែនភ្នែន ។ ព្រះពុទ្ធជាលោកនាយក ព្រះនាមសុមេធ: អង្គនោះ ជាបុរសដ៏ប្រសើរ ទ្រង់គង់ចូលសមាធិ អស់ ៧ យប់ ៧ ថ្ងៃ ។ ខ្ញុំកែអម្រែកបរិក្ខារ សំដៅចូលទៅកាន់ព្រៃ

តត្ថទ្ទសាសឹ សម្ពុទ្ធំ ឱឃតិណ្ណមនាសវំ ។
សម្មជ្ជនឹ គហេត្វាន សម្មជ្ជិត្វាន អស្សមំ
ចតុទណ្ឌេ ឋបេត្វាន អកាសឹ មណ្ឌបំ តទា ។
សាលបុប្ផំ គហេត្វាន មណ្ឌបំ ឆាទយឹ អហំ
បសន្នចិត្តោ សុមនោ អវន្ទឹ លោកនាយកំ(១) ។
យំ វទន្តិ សុមេធោតិ ភូរិបញ្ញំ សុមេធសំ
ភិក្ខុសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
ពុទ្ធស្ស គិរមញ្ញាយ សព្វេ ទេវា សមាគមុំ
អសំសយំ ពុទ្ធសេដ្ឋោ ធម្មំ ទេសេតិ ចក្ខុមា ។
សុមេធោ នាម សម្ពុទ្ធោ អាហុតីនំ បដិគ្គហោ
ទេវសង្ឃេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មេ សត្តាហំ មណ្ឌបំ ធារយិ សាលឆាទនំ(២)
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។

---

១ ឱ. ម. អភិវន្ទឹ តថាគតំ ។ ២ ឱ. ម. សាលឆាទិតំ ។

ហើយឃើញព្រះសម្ពុទ្ធ ក្នុងវ៉ៃត្រនោះ ព្រះអង្គមានទុយ:ធ្ងន់ ហើយ មិនមានអាសវ: ។ គ្រានោះ ខ្ញុំកាន់អំបោសបោសអាស្រម ហើយលើកឈើ ៤ កំណាត់ បញ្ជ្រាធ្វើជាបាវ ។ ខ្ញុំមានចិត្តជ្រះថ្លា មានចិត្តរីករាយ បានយកផ្ការ៉ាយប្រក់បាវ ហើយថ្វាយបង្គំព្រះលោកនាយក ។ ពួកជនតែងហៅនូវព្រះសម្ពុទ្ធអង្គណា ដែលទ្រង់មានបញ្ញាជ្រួចផ្ទៃដី មានបញ្ញាស្អ ថាសុមេធ: ព្រះសម្ពុទ្ធអង្គនោះទ្រង់គង់ក្នុងពួកភិក្ខុ ហើយ បានសម្តែងគាថា ដូចខាងក្រោមនេះ ។ ពួកទេវតាទាំងអស់ បានដឹងព្រះពុទ្ធដីការបស់ព្រះពុទ្ធហើយ ក៏មកជួបជុំ ប្រាប់គ្នាថា ព្រះពុទ្ធដ៏ប្រសើរ ព្រះអង្គមានបក្ខ នឹងសម្តែងធម៌ដោយឥតសង្ស័យ ។ ព្រះសម្ពុទ្ធព្រះនាមសុមេធ: ព្រះអង្គគួរទទួលនូវគ្រឿងបូជា ទ្រង់គង់ក្នុងកណ្តាលពួកទេវតា ហើយត្រាស់គាថាទាំងនេះថា

បុគ្គលណា ចាំងបាវដែលប្រក់ដោយផ្ការ៉ាយ ថ្វាយ តថាគត អស់ ៧ ថ្ងៃ តថាគត នឹងសម្តែងសរសើរបុគ្គលនោះ អ្នកទាំងឡាយ ចូរចាំស្តាប់តថាគតសម្តែងចុះ ។

បឋមំ ភត្តាភិហារបទានំ

ទេវភូតោ មនុស្សោ វា ហេមវណ្ណោ ភវិស្សតិ
បហូតភោគោ ហុត្វាន កាមភោគី ភវិស្សតិ ។
សដ្ឋី(១) នាគសហស្សានិ សព្វាលង្ការភូសិតា
សុវណ្ណកច្ឆា មាតង្គា ហេមកប្បនិវាសសា ។
អារុឡ្ហា គាមណីយេភិ តោមរង្កុសបាណិភិ
សាយំ បាតោ ឧបដ្ឋានំ អាគច្ឆិស្សន្តិមំ នរំ ។
តេហិ នាគេហិ បរិវុតោ រមិស្សតិ អយំ នរោ
សដ្ឋី អស្សសហស្សានិ សព្វាលង្ការភូសិតា ។
អាជានីយា ច ជាតិយា សិន្ធវា សីឃវាហនា
អារុឡ្ហា គាមណីយេភិ ឥល្លិយាចាបធារិភិ(២) ។
បរិវារេស្សន្តិមំ និច្ចំ ពុទ្ធបូជាយិទំ ផលំ
សដ្ឋី រថសហស្សានិ សព្វាលង្ការភូសិតា ។
ទីបា អថោបិ វេយ្យគ្ឃា សន្នទ្ធា ឧស្សិតទ្ធជា
អារុឡ្ហា គាមណីយេភិ ចាបហត្ថេហិ វម្មិភិ(៣) ។

---

១ ឱ. សដ្ឋី ។ ២ ឱ. ឥល្លិយាចាបធារិហិ ។ ៣ ឱ. ម. វម្មិហិ ។

ភទ្ទលិត្ថេរាបទាន ទី ១

បុគ្គលនោះ បើបានកើតជាទេវតា ឬកើតជាមនុស្ស នឹងមាន
សម្បូរដូចមាស ជាអ្នកមានភោគៈច្រើន បរិភោគកាមគុណ
ជាប្រក្រតី ។ ដំរី ៦០ ពាន់ ដែលគេស្ងួតស្អាត ដោយ
គ្រឿងប្រដាប់ គ្រប់យ៉ាង ជាដំរីមានខ្សែដង្ហ ន់មាស ប្រ-
កបដោយគ្រឿងតាក់តែងក្សាល ជាវិការៈនៃមាស ដែល
ពួកហ្នាដំរី មានដៃកាន់លំពែងស្នែងក្របីនិងកន្ទ្រេ ដុះមក
កាន់ទីបម្រើនរៈនេះ ពល់ពេលល្ងាចព្រឹក ។ ឯនរៈនេះ
នឹងមានពួកដំរីនោះចោមរោម ហើយសប្បាយរីករាយ សេះ
៦០ ពាន់ ដែលគេស្ងួតស្អាត ដោយគ្រឿងប្រដាប់គ្រប់ចៃប
ជាសេះអាជានេយ្យ និងសេះសន្ធពពីកំណើត ជាពាហនៈ
លឿន មានពួកនាយសារថី ទ្រទ្រង់នូវខ្សែលនិងធ្នូ ឡើងដុះ
នឹងចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃពុទ្ធបូជា ។
រថ ៦០ ពាន់ ដែលគេតាក់តែងដោយប្រដាប់គ្រប់យ៉ាង ចិទ
ចុំងដោយស្បែកខ្លាដំបងនិងខ្លាធំ គេចងល្អហើយលើកទង់
ជ័យ មានពួកនាយសារថី មានដៃកាន់ធ្នូនិងខ្សែ ឡើងដុះ

បរិចារេស្សន្តិ មំ និច្ចំ ពុទ្ធបូជាយិទំ ផលំ
សដ្ឋី តាឡសហស្សានិ បរិបុណ្ណានិ សព្វសោ ។
បហូតជជជញ្ញានិ សុសមិទ្ធានិ សព្វសោ
សទា ទាតុករិស្សន្តិ ពុទ្ធបូជាយិទំ ផលំ ។
ហត្ថី អស្សា រថា បត្តី សេនា ច ចតុរង្គិនី
បរិចារេស្សន្តិ មំ និច្ចំ ពុទ្ធបូជាយិទំ ផលំ ។
អដ្ឋារសេ កប្បសតេ[១] ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច ចក្កវត្តិ ភវិស្សតិ ។
សតានំ តីណិក្ខត្តុំ ច ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ ។
តឹសកប្បសហស្សម្ហិ ឱក្កាកកុលសម្ភវោ
គោតមោ នាម នាមេន សត្ថា លោកេ ភវិស្សតិ ។
តស្ស ធម្មេសុ ទាយាទោ ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។

---

១ ឱ. អដ្ឋារសំ កប្បសតំ ។

នឹងចោមរោមបុគ្គលនោះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ ស្រុកសួយ ៦០ ពាន់ បរិបូណ៌ដោយសព្វគ្រប់ ជាស្រុកមានទ្រព្យនិងស្រូវជាច្រើន ជារបស់សម្រេចល្អ ដោយប្រការពាំងពួង នឹងកើតមានប្រាកដសព្វកាល នេះជាផលនៃពុទ្ធបូជា ។ សេនាមានអង្គ ៤ គឺ ដំរី សេះ រថ ពលថ្មើរជើង នឹងមកចោមរោមបុគ្គលនេះជានិច្ច នេះជាផលនៃពុទ្ធបូជា ។ បុគ្គលនោះ នឹងរីករាយ ក្នុងទេវលោក អស់ ១.៨០០ កប្ប នឹងបានកើតជាស្តេចចក្រពត្តិ អស់ ១ ពាន់ដង ។ នឹងសោយទេវរាជ្យ អស់ ៣ រយដង នឹងសោយបទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ។ ក្នុងទៀ ៣០ ពាន់កប្ប នឹងមានព្រះសាស្តា ព្រះនាមគោតម កើតក្នុងត្រកូល នៃព្រះបាទឧក្កាករាជ ត្រាស់ដឹងក្នុងលោក ។ (ព្រះសុមេធសម្មុទ្ធត្រាស់ថា) ខ្ញុំនឹងបានទទួលមតិកក្នុងធម៌ ជាឧរសដែលធម៌ និម្មិតហើយ របស់ព្រះសាស្តានោះ ជាបុគ្គលគំណត់ដឹងនូវអាសវៈ:ពាំងពួង ឥតមានអាសវៈ ។

បឋមំ ញាណិត្ថេរាបទានំ

តឹសកប្បសហស្សម្ហិ អទ្ទសំ លោកនាយកំ
ឯកត្តំ ឧបាគាយ គវេសី អមតំ បទំ ។
លាភា មយ្ហំ សុលទ្ធំ មេ យមហំ ញាមិ សាសនំ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
នមោ តេ បុរិសាជញ្ញ នមោ តេ បុរិសុត្តម
ញាណំ បដិកិត្តេត្វាន(១) បត្តោម្ហិ អមតំ(២) បទំ ។
យំ យំ យោនូបបជ្ជាមិ ទេវត្តំ អថ មានុសំ
សព្វត្ថ សុខិតោ ហោមិ ផលម្មេ ញាណកិត្តនេ ។
ឥទំ បច្ឆិមកំ មយ្ហំ ចរិមោ វត្តតិ ភវោ
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ. ម. តវ ញាណំ បកិត្តេត្វា ។ ២ ខ. ម. អចលំ ។

ភគ្គលិត្ថេរាបទាន ទី ១

ក្នុងរវាង ៣០ ពាន់កប្ប ខ្ញុំបានឃើញព្រះលោកនាយក
អាស្រ័យនូវចន្ទោះនេះ ហើយសូរសៀងរាក នូវអមតបទ គឺ
និព្វាន ។ ខ្ញុំឈ្មោះថាមានលាភហើយ អត្តភាពជាមនុស្ស
ឈ្មោះថាខ្ញុំបានល្អហើយ ព្រោះខ្ញុំបានដឹង នូវពាក្យប្រៀន
ប្រដៅ នៃព្រះពុទ្ធ ដ្ឋាបី ខ្ញុំបានដល់តាមលំដាប់ហើយ
ពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។
បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្តារ ចំពោះ
ព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមនមស្តារ
ចំពោះព្រះអង្គ លុះខ្ញុំពោលសរសើរ ចំពោះព្រះញាណរួច
ហើយ ក៏បានដល់នូវអមតបទ គឺនិព្វាន ។ ខ្ញុំចូលទៅកើត
ក្នុងកំណើតណា ។ ពោះជាទេវតា ឬជាមនុស្ស ខ្ញុំរមែង
បានសេចក្តីសុខ ក្នុងទីតាំងពួង នេះជាផលរបស់ខ្ញុំ ក្នុង
ការពោលសរសើរញ្ញាណ ។ នេះពាក់កាយជាខាងក្រោយ
បំផុតរបស់ខ្ញុំ ភពជាទីបំផុតកំពុងប្រព្រឹត្តទៅ ខ្ញុំជាបុគ្គលមិន
មានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវចំណង ។

កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ភទ្ទាលិ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ភទ្ទាលិត្ថេរស្ស អបទានំ សមត្តំ ។

ទុតិយំ ឯកឆត្តិយត្ថេរាបទានំ

(២) ចន្ទភាគានទីតីរេ អស្សមោ សុកតោ មម
សុសុទ្ធបុឡិនាកិណ្ណោ បណ្ណសាលា សុមាបិតា ។

កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវចំណង ។ ឱ ! ដំណើរដែលខ្ញុំមកក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះភទ្ទាលិត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ភទ្ទាលិត្ថេរាបទាន ។

ឯកឆត្តិយត្ថេរាបទាន ទី ២

(២) ខ្ញុំបានធ្វើអាស្រមដ៏ល្អ ចាក់ដីខ្សាច់ដ៏ស្អាត ហើយសាងបណ្ណសាលា យ៉ាងល្អ ទៀបឆ្នេរស្ទឹងចន្ទភាគា ។

ទុតិយំ ឯកច្ឆត្តិយត្ថេរាបទានំ

ឧត្តានកូលា នទិកា សុបតិត្ថា មនោរមា
មច្ឆកច្ឆបសម្បន្នា សុំសុមារនិសេវិតា ។
អច្ឆា មយូរទីបី ច ករវិកា ច សាលិកា
កូជន្តិ សព្វទា ឯតេ សោភយន្តា មមស្សមំ ។
កោកិលា មញ្ជុភាណី ច ហំសា ច មធុរស្សរា
អភិកូជន្តិ តេ តត្ថ សោភយន្តា មមស្សមំ ។
សីហា ព្យគ្ឃា វរាហា ច វកកោកតរច្ឆយោ
គិរិទុគ្គម្ហិ(១) នាទេន្តិ សោភយន្តា មមស្សមំ ។
ឯណីមិគា ច សរភា ភេរណ្ឌា(២) សូករា ពហូ
គិរិទុគ្គម្ហិ នាទេន្តិ សោភយន្តា មមស្សមំ ។
ឧទ្ទាលកា ច ចម្បកា បាដលី សិន្ទុវារិកា
អធិមុត្តា(៣) អសោកា ច សោភយន្តា មមស្សមំ(៤) ។

---

១ ឱ. គិរិទុគ្គំបិ ។ ២ ភេទណ្ឌា ។ ៣ ឱ. អតិមុត្តា ។ ៤ ឱ. បុប្ផន្តិ មម អស្សមេ ។ ម. សោភយន្តិ មមស្សមំ ។

ស្ងួត (នោះ) មានប្រាំផាយ មានកំពង់ពស្ម ជាទីកក
ពយនៃចិត្ត បរិបូណ៌ដោយសត្វត្រី និងអណ្តើក មានសត្ត
ក្រពើនៅអាស្រ័យ ។ ពួកសត្វទ្រាយ ក្ងោក ទ្រាដំបង ការ៉ាត
និងសាលិកា តែងបន្ទឹសំឡេង សព្ទ ។ កាល សត្វ៣ន៏ុ
ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកតាវ៉ៅ មានសំឡេងពីរោះ
និងហង្សមានស្ងួរសព្ទពីរោះ តែងយំធ្វើយនូងគ្នា (សព្ទ ។
កាល) សត្វ៣ន៏ុ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ក្នុងទីនោះ ។
ពួកសីហៈ ទ្រាធ ជ្រូក ក្ងុក ផ្ទៃព្រៃ និងទ្រាវ៉ិន តែង
បន្ទឹសំឡេងកែ្ករជ្រោះកុ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួក
ម្រីគ្រាយ ម្រីគ្ងីន ចចក ន៏ងជ្រូកជាច្រើន តែងបន្ទឹ
សំឡេងកែ្ករជ្រោះកុ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើម
ពជ្រ ដើមចម្ប៉ា ដើមជ្រនៀង ដើមឈើកូ៉ង ដើម
រ៉ាំដ្ឋល និងដើមអសោក ក៏ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។

អង្កោលា យូថិកា ចេវ សត្តបណ្ណា ពិម្ពិជាលិកា(១)
កណិកា កណិការា ច(២) បុប្ផន្តិ មម អស្សមេ(៣) ។
នាគា សាលា ច សលឡា បុណ្ឌរីកេត្ថ បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភន្តិ មម អស្សមេ(៤) ។
អស្សដ្ឋា អសនា ចេត្ថ(៥) មហានាមា ច បុប្ផិតា
សាលា(៦) ច កង្គុបុប្ផា ច សោភន្តិ មម អស្សមេ ។
អម្ពា ជម្ពូ ច តិលកា នីបា ច សាលកល្យាណី
ទិព្វា គន្ធា សម្បវន្តា សោភយន្តិ មមស្សមំ ។
អសោកា ច កបិដ្ឋា ច ភគិនិមាលា ច បុប្ផិតា
ទិព្វា គន្ធា សម្បវន្តា សោភយន្តិ មមស្សមំ ។
កទម្ពា កទលី ចេវ ឥសិមុគ្គា ច ពេបិតា
ធុវំ ផលានិ ធារេន្តិ សោភយន្តិ មមស្សមំ ។

---

១ ម. សត្តលិពិម្ពជាលិកា ។ ២ ឱ. កណ្ណិកា កណ្ណិការា ច ។ ម. កណ្ណិការា ច បុប្ផន្តិ ។ ៣ ម. សោភយន្តា មមស្សមំ ។ ៤ ម. សោភយន្តិ មមស្សមំ ។ ៥ ម. អង្កុនា អសនាបេត្ថ ។ ៦ ម. ផលា ច ។

ពួកដើមអង្ក្រាស ដើមយុថ្ម ដើមសត្តបាណ ដើមចាស ដើមកន្ទ-ស នឹងដើមគណិការ បញ្ចេញផ្ការីកអស្រមរបស់ខ្ញុំ ។ ពួកដើមខ្ទឹង ដើមកំផង ដើមស្រល់ នឹងដើមស្វាយ ស មានផ្ការីកនៅកន្ទ-ម៉ីនោះ ក្លិនជាទ្ធិសាយកាយ ធ្វើអ-ស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមពោធិ ដើមធ្ន ដើមជន្ទាត់ ដៃ ដើមកំផង និងដើមផ្ការ៉ូ មានផ្ការីក ធ្វើអស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមស្វាយ ដើមត្រីង ដើមជង្ក្រៀបក្តាម ដើមកំផអន្ទ ក់ និងដើមក្ងៅនាង ក្លិនជាទ្ធិត្ត្ក្ងអូបសាយ កាយ ធ្វើអស្រមរបស់ខ្ញុំឲ្យល្អ ។ ពួកដើមអសោក ដើម ខ្ទ ត ដើមនួនស្រ ី មានផ្ការីក ក្លិនជាទ្ធិសាយកាយ ធ្វើអ-ស្រមរបស់ខ្ញុំឲ្យល្អ ។ ដើមកូម ដើមបេត ដើមសណ្ណ ត ព្រៃ ដែលគេដាំ ទ្ទ្ទ ន ផ្ទ ជានិច្ច ធ្វើអស្រមរបស់ខ្ញុំឲ្យល្អ ។

ទុតិយំ ឯកច្ចត្តិយគ្គោបទានំ

ហរីតកា អាមលកា   អម្ពា ជម្ពូ វិភេទកា
កោលា ភល្លាតកា ពេល្លា ផលិនោ មម អស្សមេ ។
អវិទូរេ ពោក្ខរណី   សុបតិត្ថា មនោរមា
មន្ទាលកេហិ សញ្ឆន្នា   បទុមុប្បលកេហិ ច ។
គព្ភំ គណ្ហន្តិ បទុមា   អញ្ញេ បុប្ផន្តិ កេសរី
ឱបត្តកណ្ណិកា ចេវ   បុប្ផន្តិ មម អស្សមេ ។
បាឋីនា បាវុសា មច្ឆា   វលជា មុញ្ជរោហិតា
អច្ឆោទកម្ហិ វិចរំ   សោភយន្តិ មមស្សមំ ។
នយិតា អម្ពគន្ធិ ច   អនុកុលេ ច កេតកា
ទិព្វា គន្ធា សម្បវន្តា   សោភយន្តិ មមស្សមំ ។
មធុភិសេហិ សវន្តិ   ខីរសប្បិមុឡាលិភិ
ទិព្វា គន្ធា សម្បវត្តា   សោភយន្តិ មមស្សមំ ។

ពួកដើមសម៉ ដើមកន្ទួតព្រៃ ដើមស្វាយ ដើមត្រីផ ដើមសម៉ពិភេទ ដើមក្រជៅ ដើមពក់ខ្ទៅ ដើមញ្ញ៉ មានផ្លែ ជិតអាស្រមរបស់ខ្ញុំ ។ នៅទីជិតស្រះបោក្ខរណី មានកំពង់ពបស្ទ្ធ ជាទីរីករាយចិត្ត ដ៏ដេរដាសដោយលំចង ផ្កាឈូក និងផ្កាទុម្ពុល ។ ពួកដើមឈូក កំពុងចាប់ផ្លែ (នោម) ពួកដើមឈើ មានកេសរជ ១ ១ បញ្ចេញផ្ការីក មានទង ដើមកណ្ណិការមានស្លឹកជ្រុះ បញ្ចេញផ្កា នៅទៀបអាស្រមរបស់ខ្ញុំ ។ ពួកត្រីស្វាត ត្រីក្ស ត្រីក្រាញ់ ត្រីសណ្ឋាយ និងត្រីធ្ងិន កំពុងគ្រាប់ទៅមក ក្នុងទឹកថ្ម ធ្វើអាស្រមរបស់ខ្ញុំឲ្យស្អ ។ ពួកដើមនយិតាត្រីក្ស ដើមស្វាយក្រអូប ដើមកាកេត មាននៅទៀបលំជាប់ច្រាំង ក្ងិនជាទិព្ធសាយកាយទៅ ធ្វើអាស្រមរបស់ខ្ញុំឲ្យស្អ ។ ក្ងិនជាទិព្ធសាយកាយ ហូរចេញមកពីក្រអៅឈូក និងមើមឈូក ដូចទឹកដោះពវ និងទឹកដោះថ្ម ធ្វើអាស្រមរបស់ខ្ញុំឲ្យស្អ ។

បុឡិនា សោភនា តត្ថ អាកិណ្ណា ជលសេវិតា
ឱបុប្ផា បុប្ផិតា សេតា សោភយន្តិ មមស្សមំ ។
ផលភារភរិតា(១) ច(២) អភិឆុត្តរភាសិនោ
វាកចីរធរា សព្វេ សោភយន្តិ មមស្សមំ ។
យុគមត្តមបេក្ខន្តា(៣) និបកា សន្តវុត្តិនោ
កាមគេធេ(៤) អនបេក្ខា វសន្តិ មម អស្សមេ ។
បរូឡ្ហកច្ឆនខលោមា បង្កទន្តា រជស្សិរា
រជោជល្លធរា សព្វេ វសន្តិ មម អស្សមេ ។
អភិញ្ញាបារមិប្បត្តា អន្តលិក្ខចរា តេ
ឧគ្គច្ឆន្តា នភំ ឯតេ សោភយន្តិ មមស្សមំ ។
តេហិ សិស្សេហិ បរិវុតោ វសាមិ បវនេ តទា
រត្តិន្ទិវំ ន ជានាមិ ឈានរតិសមប្បិតោ(៥) ។

---

១ ឱ. ឯត្ថន្តរេ ចេតិ ទិស្សតិ ។ ២ ម. ផលភារេន ភរិតា ។ ៣ ឱ. យុគមត្តំ បេក្ខមានា ។ ៤ ម. កាមភោគេ ។ ៥ ឱ ម. សទា ឈានសមប្បិតោ ។

ផ្ទៃកខ្ទាប់ដ៏ល្អដេរដាស ជ្រួតជ្រាបដោយទឹកកន្ធ ទ្រនោះ ទ្រឹង
ដើមសេតព្រឹក្ស មានផ្ការីកយ៉ុះកំផ្ការីក ធ្វើអាស្រមរបស់
ខ្ញុំឲ្យល្អ ។ ពួកតាបសទាំងអស់ ពេញទៅដោយការ:
គឺផ្ទ ដ ស ក ស្ងៀកសំពត់ស្បែកខ្លា ទាំងទ្រទ្រង់ទ្ទូសំពត់
សំបកឈើ ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ (ពួកតាបសទាំង
នោះ) ក្រឡេកមើលប្រមាណមួយដួងនឹម ជាបុគ្គលមាន
បញ្ញាចាស់ មានកិរិយាប្រព្រឹត្តដ៏ស្ងប់ស្ងាត់ជាប្រក្រតី មិន
មានសេចក្តីប្ចាច្ចា ក្នុងការជាប់ចំពាក់ដោយកាម នៅក្នុ
អាស្រមរបស់ខ្ញុ ។ ពួកតាបសទាំងអស់នោះ មានក្រចកនិង
ពេមក្ងៀកដុះវែង ។ មានមន្ទ្ធិលធ្ងេញ មានធ្ងលីលើក្បាល
ទ្រទ្រង់ទ្ទូវធ្ងលីនិងក្ដ្ល នៅក្នុងអាស្រមរបស់ខ្ញុ ។ ពួក
តាបសទាំងនោះ ដល់ទ្ទូវអភិញ្ញាបារមី សុទ្ធតែគ្រាប់ទៅ
ឦ្ធដ៏អាកាសបាន តាបសទាំងនុ:ះ ហោះទៅកាន់អាកាស
ធ្វើអាស្រមរបស់ខ្ញុំឲ្យល្អ ។ ត្រានោះ ខ្ញុ:មានពួកសិស្សទាំង
នោះ ចេមរេមជាបរិវារ នៅក្នុងព្រៃធំ ផ្ទ:ត ស ក ប ស ល
ដោយសេចក្តីកេ:ពយ ក្នុ:ឈាន ឥតដ:ងយ:ន:ងថ្ងៃ ។

ទុតិយំ ឯកប្បត្តិយត្ថេរាបទានំ

ភគវា តម្ហិ សមយេ អត្ថទស្សី មហាមុនិ
តមន្ធការំ នាសេន្តោ ឧប្បជ្ជិ លោកនាយកោ ។
អថ អញ្ញតកេ សិស្សោ អាគច្ឆិ មម សន្តិកេ
មន្តេ អជ្ឈេតុកាមោ សោ ឆឡង្គំ នាម លក្ខណំ ។
ពុទ្ធោ លោកេ សមុប្បន្នោ អត្ថទស្សី មហាមុនិ
ចតុសច្ចំ បកាសេន្តោ ទេសេសិ(១) អមតំ បទំ ។
តុដ្ឋហដ្ឋោ បមុទិតោ ធម្មន្តរគតាសយោ(២)
អស្សមា អភិនិក្ខម្ម ឥទំ វចនមព្រវី ។
ពុទ្ធោ លោកេ សមុប្បន្នោ ទ្វត្តឹសវរលក្ខណោ
ឯថ សព្វេ គមិស្សាម សម្មាសម្ពុទ្ធសន្តិកេ
ឱវាទបដិករា តេ សទ្ធម្មេ បារមឹ គតា
សាធូតិ សម្បដិច្ឆឹសុ ឧត្តមត្ថំ គវេសកា ។

---

១ ឱ. ម. ទេសេតិ ។ ២ ឱ. ធម្មន្តរគតាសិយោ ។

ឯកជ្ជត្ថិយត្ថេរាបទាន ទី ២

សម័យនោះ ព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ជាអ្នកប្រាជ្ញធំ ព្រះអង្គជានាយកនៃសត្វលោក ទ្រង់កំចាត់បង់នូវផ្ទាំងងងឹតអន្ធការ ទ្រង់កើតឡើង ក្នុងលោក ។ គ្រានោះ មានសិស្សមួយរូប ចូលមកកន្លែងសំណាក់ខ្ញុំ សិស្សនោះមានប្រាជ្ញានឹងរៀន នូវមន្តជាច្រើន ឈ្មោះឆព្យាគ្គលក្ខណៈ ។ ព្រះពុទ្ធព្រះនាមអត្ថទស្សី ជាអ្នកប្រាជ្ញដ៏ប្រសើរផុត ទ្រង់កើតឡើងក្នុងលោក កំពុងប្រកាស នូវសច្ចៈ ៤ ហើយសម្តែងនូវអមតបទគឺនិព្វាន ។ ខ្ញុំមានសេចក្តីត្រេកអរស្រស់ស្រាយរីករាយ ជាទីអាស្រ័យនៅ នៃពួកអ្នកមានចិត្តជាធម្មិ ចេញអំពីអាស្រម ហើយពោលពាក្យនេះថា ព្រះពុទ្ធកើតឡើងហើយ ក្នុងលោក ទ្រង់មានលក្ខណៈដ៏សំខាន់ ៣២ ប្រការ ដូច្នេះ អ្នកពាល់គ្នាចូរមក យើងនឹងទៅកន្លែងសំណាក់នៃព្រះសម្មាសម្ពុទ្ធ ។ ពួកតាបសទាំងនោះ ជាអ្នកធ្វើតាមនូវពាក្យខ្ញុំ ដល់នូវចារមីកន្លែងព្រះសន្ទម ជាអ្នកសៀងរក នូវប្រយោជន៍ដ៏ប្រសើរ ចេញទទួលថាសាធុ ។

សុត្តន្តបិដកៃ ខុទ្ទកនិកាយស្ស អបទានំ

ជជាការកវិតា តេ អជ្ជុត្តរាសិ ជោ
ខុត្តមត្ថ្ នវសន្ថ្ ជិ ក្ខូ ម ឹ ស ុ រ ជ ា ត ជ ា ។
ភ ក ្ ក ា ត ម ្ ហ ិ ្ ស ម យ េ អ ត ្ ត ជ ស ្ ្ ម ហ ា យ ស ោ
ជ ត ុ ស ច ្ ច ং ប ក ា ស េ ន ្ ត ោ ជ េ ស េ ស ិ អ ម ត ং ប ទ ং ។
ស េ ត ច ្ ឆ ត ្ ត ং ភ ហ ោ ត ្ ា ជ ពុ ទ ្ ធ េ ន ្ ទ ជ ្ ្ ជ ារ យ ึ
ឯ ក ា ហ ং ជ ារ យ ិ ត ្ ា ជ ពុ ទ ្ ធ េ ន ្ ទ ং អ ា ន ្ ទ ិ ហ ং ។
អ ត ្ ត ជ ស ្ ្ ត ុ ភ ក ្ ក ា លោ ក ជ េ ដ ្ ឋ ោ ជ ភ ា ស ោ
ភ ិ ក ្ ខ ូ ស ង ្ ឆ ং ជ ិ ស ី ទ ិ ត ្ ា ឥ ម ា ត ា ជ ា អ ភ ា ស ថ ។
យ ោ ម េ ជ ត ្ ត ម ជ ា ម េ ស ិ ជ ស ន ្ ធ ោ ម េ ហ ិ ជ ា ណ ិ ភ ិ
ត ម ហ ং ភ ិ ត ្ ត យ ិ ស ្ ្ ជ ា ម ិ ស ុ ណ ា ថ ម ម ភ ា ស ោ ។
ឥ ម ស ្ ្ ជ ា យ ម ា ជ ស ្ ្ ជ ោ រ ត ្ ត ោ អ ថ ម ា ជ ុ ស ោ
ជ ា រ ស ្ ្ ជ ិ ជ ា ជ ត ং ជ ត ្ ត ং ជ ត ្ ត ជ ា ជ ស ្ ្ ជ ិ ং ជ ល ং ។

ពួកតាបសទាំងនោះ សឹងពេញទៅដោយការ: គឺផ្ទ្ធ ១ សក់ ១ ស្ងៀកពាក់ស្បែកខ្លា កំពុងស្វែងរកប្រយោជន៍ដ៏ទុត្តម ចេញ ចាកត្រៃ ក្នុងកាលនោះ ។ គាប់ជួនសម័យនោះ ព្រះមាន ព្រះភាគ ព្រះនាមអត្ថទស្សី ព្រះអង្គមានយសធំ កំពុង ប្រកាសសច្ច: ៤ សម្តែងនូវអមតបទ គឺនិព្វាន ។ ខ្ញុំបាន កាន់ស្មៅតន្ត្រ ចាំងថ្វាយព្រះពុទ្ធដ៏ប្រសើរ លុះចាំងថ្វាយ អស់មួយថ្ងៃហើយ ខ្ញុំថ្វាយបង្គំព្រះពុទ្ធដ៏ប្រសើរ ។ ចំណែក ខាងព្រះមានព្រះភាគ ព្រះនាមអត្ថទស្សី ទ្រង់ជាឫសីក្នុង លោក ជានរ:ដ៏ប្រសើរ ទ្រង់គង់ក្នុងពួកភិក្ខុ ហើយត្រាស់ នូវគាថាទាំងនេះថា

បុគ្គលណាមានចិត្តជ្រះថ្លា ចានចាំងតន្ត្រថ្វាយតថាគត ដោយដៃរបស់ខ្លួន តថាគត នឹងសរសើរបុគ្គលនោះ អ្នក ទាំងឡាយ ចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនេះ កាលកើតជាទេវតា ឬកើតជាមនុស្ស ពួកជននឹងចាំងតន្ត្រ ឲ្យ សព្វ ១ កាល នេះជាផល នៃការថ្វាយតន្ត្រ ។

ទុតិយំ ឯកច្ឆត្តិយត្ថេរាបទានំ

សត្តសត្តតិកប្បានិ   ទេវលោកេ រមិស្សតិ
សហស្សក្ខត្តុំ រាជា ច   ចក្កវត្តិ ភវិស្សតិ ។

សត្តសត្តតិក្ខត្តុញ្ច   ទេវរជ្ជំ ករិស្សតិ
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ ។

អដ្ឋារសេ កប្បសតេ   គោតមោ សក្យបុង្គវោ
តមន្ធការំ នាសេត្វា   ឧបជ្ជិស្សតិ ចក្ខុមា ។

តស្ស ធម្មេសុ ទាយាទោ   ឱរសោ ធម្មនិម្មិតោ
សព្វាសវេ បរិញ្ញាយ   និព្វាយិស្សតិនាសវោ(១) ។

យតោ អហំ កម្មមកំ   ឆត្តំ ពុទ្ធស្ស ធារយឹ
ឯត្ថន្តរេ ន ជានាមិ   សេតច្ឆត្តំ អធារិតំ ។

ឥទំ បច្ឆិមកំ មយ្ហំ   ចរិមោ វត្តតេ ភវោ
ឆត្តធារណមជ្ជាបិ   វត្តតេ និច្ចកាលិកំ ។

---

១ ម. វិហរិស្សតិនាសវោ ។

បុគ្គលនោះ នឹងរីកចម្រើន ក្នុងទេវលោក អស់ ៧៧ កប្ប នឹងបានជាស្តេចចក្រពត្តិ អស់ ១.០០០ ដង ។ ម្យ៉ាងទៀត បុគ្គលនោះ នឹងបានសោយទេវភាព ជាស្តេចនៃទេវតា អស់ ៧៧ ដង នឹងសោយបរទេសភាព ដ៏ធំទូលាយ ពាប់ បានមួយអសង្ខ្យជាតិ ។ ក្នុងវេលា ១.៨០០ កប្ប ព្រះ ពុទ្ធព្រះនាមគោតម ជាសាក្យដ៏ប្រសើរបំផុត ព្រះអង្គមាន ចក្ខុ ទ្រង់កំចាត់បង់ទ្រង់ងងឹតអន្ធការ នឹងកើតឡើង ។ បុគ្គលនោះ នឹងបានទទួលមតិក ក្នុងធម្មវិជ្ជារបស់ព្រះពុទ្ធអង្គ នោះ ជាឧសវៈដែលធម្មនិម្មិតហើយ កំណត់ដឹងនូវអាសវៈ ទាំងអស់ ជាអ្នកមិនមានអាសវៈ នឹងបរិនិព្វាន ។

កាលណា ខ្ញុំបានធ្វើនូវកុសលកម្ម គឺចាំងធ្លក្ដាយព្រះ ពុទ្ធ ក្នុងចន្លោះនេះ ខ្ញុំមិនដែលស្គាល់ស្ងួតធ្លក ដែល គេមិនចាំងឲ្យខ្ញុំឡើយ ។ នេះពាងកាយ ជាទីបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ចំណែកការចាំង ធ្លកលើកល្ប អស់កាលជានិច្ច មានដកបដល់ថ្ងៃនេះ ។

អហោ មេ សុកតំ កម្មំ អត្ថទស្សិស្ស តាទិនោ
សព្ពាសវបរិក្ខីណោ(១) ជត្ថិ ទានិ បុនព្ភវោ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឯកច្ឆត្តិយោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

ឯកច្ឆត្តិយត្ថេរស្ស អបទានំ សមត្តំ ។

---

១ សព្ពាសវា បរិក្ខីណាតិ សុឆិក្ខិត្តរំ ។

ឱហ្ន៎ ! អំពើល្អខ្ញុំធ្វើដោយប្រពៃហើយ ចំពោះព្រះពុទ្ធ ព្រះនាមអត្ថទស្សី ព្រះអង្គប្រកបដោយតាទិគុណ ខ្ញុំមានអាសវៈទាំងពួង អស់រលីងហើយ ឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្ទឹង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធ របស់ខ្ញុំជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើតាមរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកបត្តិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកបត្តិយត្ថេរាបទាន ។

តតិយំ តិណសូលកឆាទនិយត្ថេរាបទានំ

(៣) ជាតិជរញ្ច មរណំ បច្ចវេក្ខឹ អហំ តទា
ឯកកោ អភិនិក្ខម្ម បព្វជឹ អនគារិយំ ។
ចរមានោ អនុបុព្វេន គង្គាតីរំ ឧបាគមឹ
តត្ថទ្ទសាសឹ បថវឹ គង្គាតីរេ សមុណ្ណតំ(១) ។
អស្សមំ តត្ថ មាបេត្វា វសាមិ មម អស្សមេ(២)
សុកតោ ចង្កមោ មយ្ហំ នានាទិជគណាយុតោ ។
មមំ ឧបេន្តិ ច សត្តា កុជ្ជន្តិ ច មនោហរំ(៣)
រម្មមានោ សហ តេហិ វសាមិ អស្សមេ អហំ ។
មម អស្សមសាមន្តា មិគរាជា ចតុក្កមោ
អាសយា អភិនិក្ខម្ម គជ្ជិ សោ អសនី វិយ ។
នទិតេ មិគរាជេ ច ហាសោ មេ ឧទបជ្ជថ
មិគរាជំ គវេសន្តោ អទ្ទសំ លោកនាយកំ ។

---

១ ឱ. សុបុណ្ណតំ ។ ម. សមុន្នតំ ។ ២ ឱ. ម. វសាមិ អស្សមេ អហំ ។ ៣ ឱ. មមុ-
បេន្តិ ច វិស្សត្ថា កូជន្តិ ច មនោហរំ ។ ម. មំ ឧបេន្តិ ច វិស្សត្ថា កូជន្តិ ច មនោហរំ ។

តិណសូលកឆាទនិយត្ថេរាបទាន ទី ៣

(៣) កាលនោះ ខ្ញុំបានពិចារណានូវជាតិជរានិងមរណៈ ខ្ញុំតែម្នាក់ឯង ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ៗ កាលខ្ញុំសញ្ចរទៅតាមលំដាប់ បានចូលទៅកាន់ឆ្នេរនៃទន្លេគង្គា ក៏ឃើញផែនដីដុះពេញស្មើ នៅទៀបឆ្នេរទន្លេគង្គានោះ ៗ ខ្ញុំបានសាងអាស្រមត្រង់ទីនោះ ហើយនៅក្នុងអាស្រមរបស់ខ្ញុំ ទីចង្ក្រមដែលខ្ញុំបានធ្វើល្អហើយ សឹងប្រកបដោយពួកសត្វស្លាបផ្សេង ៗ ៗ ពួកសត្វតែងចូលមកជិតខ្ញុំផង បន្លឺសំឡេងគួរឲ្យជាប់ចិត្តផង ខ្ញុំត្រេកអររីករាយ ជាមួយនឹងសត្វទាំងនោះ ហើយនៅក្នុងអាស្រម ៗ ស្តេចម្រឹគមានជើង ៤ នៅជិតអាស្រមរបស់ខ្ញុំ ស្តេចម្រឹគនោះ តែងចេញអំពីលំនៅមកស្រែកគំរាមដូចជារន្ទះ ៗ កាលស្តេចម្រឹគបន្លឺសំឡេងឡើង ខ្ញុំក៏មានសេចក្តីរីករាយកើតឡើង ខ្ញុំកំពុងស្វះស្វែងរកស្តេចម្រឹគ ស្រាប់តែប្រទះឃើញព្រះលោកនាយក ៗ

ទិស្វានាហំ ទេវទេវំ　　តិស្សំ លោកគ្គនាយកំ
ហដ្ឋោ ហដ្ឋេន ចិត្តេន　　បូជយឹ នាគកេសរំ ។
ឧគ្គច្ឆន្តំវ សុរិយំ　　សាលរាជំវ បុប្ផិតំ
ឱសធីរ(១) វិរោចន្តំ　　សញ្ជីវ លោកនាយកំ ។
តវ ញាណេន សព្វញ្ញុ　　ជោតេសិ(២) មំ សទេវកំ
តុវំ អារាធយិត្វាន　　ជាតិយា បរិមុច្ចរេ ។
អទស្សនេន សព្វញ្ញុ-　　ពុទ្ធានំ សព្វទស្សិនំ
បតន្តិវីចិនិរយំ　　រាគទោសេហិ ឱត្ថដា(៣) ។
តវ ទស្សនមាគម្ម　　សព្វញ្ញុលោកនាយកំ
បមុច្ចន្តិ ភវា សព្វេ　　ផុសន្តិ អមតំ បទំ ។

---

១ ឱ ម. ឱសធីវ ។ ២ ម. មោចេសិ ។ ៣ ឱ. ម. ឱត្ថុដា ។

លុះខ្ញុំឃើញព្រះពុទ្ធ ព្រះនាមតិស្សៈ ជាទេវតាក្រៃលែងជាងទេវតា ជានាយកប្រសើរ របស់សត្វលោកហើយ ខ្ញុំមានចិត្តត្រេកអររីករាយ បានបូជាកេសរផ្កាឈូក ។ ខ្ញុំសរសើរព្រះលោកនាយក ព្រះអង្គកំពុងរុងរឿង ដូចជាព្រះអាទិត្យកាលរះឡើង ឬដូចជាស្តេចឈើមានផ្ការីក ពុំនោះសោតដូចជាផ្កាយព្រឹកថា បពិត្រព្រះសព្វញ្ញូ ព្រះអង្គទ្រង់ធ្វើខ្ញុំព្រមទាំងទេវតាឲ្យរុងរឿង ដោយញាណរបស់ព្រះអង្គ ពួកជនបានធ្វើព្រះអង្គ ឲ្យត្រេកអរហើយ រមែងរួចចាកជាតិ ។ ពួកជនដែលត្រូវរាគៈនិងទោសៈ គ្របសង្កត់ហើយ រមែងធ្លាក់ចុះក្នុងអវិចិនរក ព្រោះកិរិយាមិនឃើញ នូវព្រះសព្វញ្ញុពុទ្ធ ទ្រង់ឃើញហេតុទាំងពួង ។ ពួកសត្វទាំងអស់ រួចស្រឡះចាកភព ពាល់ត្រូវនូវអមតបទគឺព្រះនិព្វាន ព្រោះអាស្រ័យនូវការឃើញព្រះអង្គ ជាសព្វញ្ញូលោកនាយក ។

តតិយំ តិណសូលកឆាទនិយត្ថេរាបទានំ

យទា ពុទ្ធា ចក្ខុមន្តោ ឧប្បជ្ជន្តិ បភង្ករា
កិលេសេ ឈាបយិត្វាន អាលោកំ ទស្សយន្តិ តេ ។
កិត្តយិត្វាន សម្ពុទ្ធំ តិស្សំ លោកគ្គនាយកំ
ហដ្ឋោ ហដ្ឋេន ចិត្តេន តិណសូលំ អបូជយឹ ។
មម សង្កប្បមញ្ញាយ តិស្សោ លោកគ្គនាយកោ
សកាសនេ និសីទិត្វា ឥមា គាថា អភាសថ ។
យោ មំ(១) បុប្ផេហិ ឆាទេសិ បសន្នោ សេហិ បាណិភិ
តមហំ កិត្តយិស្សាមិ សុណាថ មម ភាសតោ ។
បញ្ចវីសតិក្ខត្តុញ្ច(២) ទេវរជ្ជំ ករិស្សតិ
បញ្ចសត្តតិក្ខត្តុញ្ច ចក្កវត្តិ ភវិស្សតិ ។

---

១ ម. មេ ។ ២ ឱ. ម. បញ្ចវីសតិក្ខត្តុំ សោ ។

កាលណា ព្រះពុទ្ធទាំងឡាយ ព្រះអង្គមានបញ្ញាចក្ខុ ជាអ្នកធ្វើនូវពន្ធឺកើតឡើង ព្រះពុទ្ធទាំងឡាយនោះ រមែងដុតកិលេស ហើយបង្ហាញនូវពន្ធឺក្នុងកាលនោះ ។ ខ្ញុំសរសើរព្រះសម្ពុទ្ធ ព្រះនាមតិស្ស: ជានាយកដ៏ប្រសើររបស់សត្ត-លោក ហើយបានបូជាផ្កាមួយរ៉ូត ដោយចិត្តរីករាយ ។ ឯព្រះពុទ្ធព្រះនាមតិស្ស: ជានាយកដ៏ប្រសើរនៃសត្តលោក ទ្រង់បានជ្រាបច្បាស់ នូវសេចក្តីត្រិះរិះរបស់ខ្ញុំ ទ្រង់គង់លើអាសន:របស់ព្រះអង្គ ហើយសម្តែងនូវគាថាទាំងនេះថា

បុគ្គលណាមានសេចក្តីជ្រះថ្លា បានចាំងតថាគតដោយផ្កាទាំងឡាយ ដោយដៃរបស់ខ្លួន តថាគត នឹងសរសើរបុគ្គលនោះ អ្នកទាំងឡាយចូរស្តាប់តថាគតសម្តែងចុះ ។ បុគ្គលនោះ នឹងសោយទេវរាជ្យ ជាស្តេចនៃទេវតា អស់ ២៥ ដង នឹងបានជាស្តេចចក្រពត្តិ អស់ ៧៥ ដង ។

បនេសរដ្ឋំ វិបុលំ គណោ ជាតោ អសង្ខិយំ
តស្ស កម្មស្ស និស្សន្ទា(១) បុព្វានំ បូជនាយ សោ(២) ។
សាយំ បាតោ ចយំ បោសោ បុប្ផេហិ មំ អធានយិ(៣)
បុញ្ញកម្មេន សំយុត្តោ បុរតោ បាតុភវិស្សតិ ។
យំ យំ ឥច្ឆតិ កាមេហិ តំ តំ បាតុភវិស្សតិ
សង្កប្បំ បរិបូរេត្វា និព្វាយិស្សតិនាសវោ ។
កិលេសេ(៤) ឈាបយិត្វាន សម្បជានោ បតិស្សតោ
ឯកាសនេ និសីទិត្វា អរហត្តំ អបាបុណិ(៥) ។
ចង្កមន្តោ និបជ្ជន្តោ និសិន្នោ អថវា(៦) ឋិតោ
ពុទ្ធសេដ្ឋំ សរិត្វាន វិហាសិ អហំ តទា(៧) ។
ចីវរេ បិណ្ឌបាតេ ច បច្ចយេ សយនាសនេ
តត្ថ មេ ឩនតា នត្ថិ ពុទ្ធបូជាយិទំ ផលំ ។

---

១ ម. និស្សន្ទេន ។ ២ ម. ប ។ ៣ ឱ. សីសំ ន្ហាតោ ច អយំ បោសោ បុប្ផមាកន្ទេន ចយន្តិ ទិស្សន្តិ ។ ម. សីសំ ន្ហាតោ ចយំ បោសោ បុប្ផមាចរុ ភោចយន្តិ ទិស្សន្តិ ។ ៤ ឱ. កិលេសា ។ ៥ ឱ. ម. អហត្តមបាបុណឹ ។ ៦ ឱ. ម. ឧទវា ។ ៧ ម. សទា ។

នឹងបានសោយប្រទេសកាដ្ស ដ៏ធំទូលាយ ពាប់ជាតិមិនអស់ នេះជាអានិសង្សនៃកម្ម គឺកិរិយាបូជានូវផ្កានោះ ។ បុរសនេះ ដែលបានចាំងតថាគតដោយផ្កាចាំងឡាយ ចាំងល្ងាច ចាំងព្រឹក នឹងទៅជាអ្នកប្រកបដោយបុញ្ញកម្ម ផលនឹងកើតប្រាកដចំពោះមុខ ។ បុរសនេះប្រាថ្នាវត្ថុណា ។ ដោយកាមចាំងឡាយ វត្ថុនោះ ។ នឹងកើតប្រាកដ នឹងញ៉ាំងសេចក្ដីប្រាថ្នាឲ្យពេញលេញ ជាអ្នកមិនមានអាសវៈ នឹងចរនិព្វាន ។

ខ្ញុំដុតបំផ្លាញពួកកិលេសចោលហើយ ជាអ្នកដឹងច្បាស់ចាំងមានស្នាតី អង្គុយលើអាសនៈតែមួយ ក៏បានដល់នូវព្រះអរហត្ត ។ ខ្ញុំកំពុងដើរ កំពុងដេក កំពុងអង្គុយឋិតឈរ ក៏នឹកទៅកព្រះពុទ្ធដ៏ប្រសើរ ក្នុងកាលនោះ ។ ក្នុងទីនោះ ខ្ញុំឥតមានសេចក្ដីខ្វះខាតដោយចីវរឬប្ចច្ច័យ បិណ្ឌបាតឬប្ចច្ច័យ និងសេនាសនឬប្ចច្ច័យសោះឡើយ នេះជាផលនៃពុទ្ធបូជា ។

តតិយំ តិណសូលកធារនិយត្ថេរាបទានំ

សោតាធិ បត្តា អមតំ សន្តិំ បទមនុត្តរំ
សញ្ញាសវេ បរិញ្ញាយ វិហាភមិ អនាសវោ ។
ខេ្វនុតេ ឥតោ កប្បេ យំ ពុទ្ធមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហាភមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា តិណសូលកធារនិយោ
ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

តិណសូលកធារនិយត្ថេរស្ស អបទានំ សមត្តំ ។

តិណសូលកឆាទនិយត្ថេរាបទាន ទី ៣

ឥឡូវនេះ ខ្ញុំនោះបានដល់អមតបទ គឺព្រះនិព្វាន ជាគុណជាតស្ងប់ប្រសើរ ខ្ញុំកំណត់ដឹង នូវអាសវៈទាំងពួង ជាអ្នកមិនមានអាសវៈ ។ ក្នុងកប្បទី ៩២ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធ ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញអស់ហើយ ភពទាំងពួង ខ្ញុំបានគាស់រំលើងចោលអស់ហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះតិណសូលកឆាទនិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ តិណសូលកឆាទនិយត្ថេរាបទាន ។

ចតុត្ថំ មធុមំសទាយកត្ថេរាបទានំ

(៤) នគរេ ពន្ធុមតិយា សូការិកោ អហោសហំ
ឧក្កោដកំ រន្ធយិត្វា មធុមំសម្ហិ ឱកិរឹ(១) ។
សន្និបាតំ អហំ គន្ត្វា ឯកបត្តំ អហំ គហឹ(២)
បូរយិត្វាន តំ បត្តំ ភិក្ខុសង្ឃស្សទាសហំ ។
យោ វុឌ្ឍថេរតរោ ភិក្ខុ និយ្យាទេសិ អហំ តទា(៣)
ឥមិនា បត្តបូរេន លភិស្សំ(៤) វិបុលំ សុខំ ។
ទុវេ សម្បត្តិយោ ភុត្វា សុក្កមូលេន ចោទិតោ
បច្ឆិមេ វត្តមានម្ហិ កិលេសេ ឈាបយិស្សតិ(៥) ។
តត្ថ ចិត្តំ បសាទេត្វា តាវតឹសំ អគញ្ឆិហំ(៦)
តត្ថ ភុត្វា បិវិត្វា ច លភាមិ វិបុលំ សុខំ ។
មណ្ឌបេ រុក្ខមូលេ វា បុព្វកម្មំ អនុស្សរឹ
អន្នបានាភិវស្សោ មេ អភិវស្សតិ តាវទេ ។

១ ឱ. មធុសប្បិម្ហិ អាកិរឹ ។ ២ ឱ. គហេសហំ ។ ៣ ឱ. ម. យេត្ថ ថេរតរោ ភិក្ខុ និយ្យាទេសិ មមំ តទាតិ ទិស្សន្តិ ។ ៤ ឱ. ម. លភស្សុ ។ ៥ អឈាបយិស្សន្តិ យុត្តតរមេវ ។ ៦ ឱ. ម. អគច្ឆហំ ។

មធុមំសទាយកត្ថេរាបទាន ទី ៤

(៤) ខ្ញុំជាអ្នកសម្ងាប់ជ្រូក នៅក្នុងក្រុងពន្ធមតី បានចំអិនគ្រឿងទេស ហើយពេយលើសាច់មានរស់ធ្ងាញ់ ។ ខ្ញុំចូលទៅកាន់ទីប្រជុំ ហើយបានយកបាត្រមួយ មកដាក់បំពេញដោយសាច់ធ្ងាញ់នោះ ហើយប្រគេនដល់ព្រះកិក្ខុសង្ឆ ។ កាលនោះ កិក្ខុអង្គណាជាថេរៈ ចាស់ជាងគេ ខ្ញុំក៏ប្រគេនកិក្ខុនោះ ខ្ញុំបាននូវសេចក្តីសុខធំទូលាយ ដោយសារការបំពេញបាត្រ ដោយសាច់ធ្ងាញ់នោះ ។ ខ្ញុំបានទទួលនូវសម្ឆត្តិទាំងពីរ ត្រូវកុសលមូលជាស់គ្នឿន ក៏បានដុតបំផ្លាញកិលេស ក្នុងបច្ចិមភពដែលកំពុងប្រព្រឹត្តទៅ ។ ខ្ញុំធ្វើចិត្តឲ្យជ្រះថ្លាក្នុងទីនោះហើយ បានទៅកើតឯឋានតាវត្តិង្ឆ ខ្ញុំធ្លាក់ធ្លាក ផ្ទាក ផ្ទាក ។ ខ្ញុំតែងរលឹកឃើញនូវបុព្វកម្ម ក្នុងមណ្ឌប ឬទៀបគល់ឈើ ក្ងៀងគ្រាយនិងទ្រ ។ ខ្ញុំតែងបង្ហុរចុះដល់ខ្ញុំ ក្នុងខណៈនោះ ។

ចតុត្ថំ មធុមំសទាយកត្ថេរាបទានំ

ឥទំ បច្ឆិមកំ មយ្ហំ ចរិមោ វត្តតេ ភវោ
ឥធាបិ អន្នបានំ មេ វស្សតេ សព្វកាលិកំ ។
តេនេវ មធុទានេន(១) សន្ធាវិត្វា ភវេ អហំ
សព្វាសវេ បរិញ្ញាយ វិហរាមិ អនាសវោ ។
ឯកនវុតេ ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ មធុទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។

---

១ ឱ. មំសទានេន ។

នេះរាងកាយខាងក្រោយបំផុតរបស់ខ្ញុំ ភពជាទីបំផុតរបស់ខ្ញុំ កំពុងប្រព្រឹត្តទៅ ចំណែកខាងបាយនិងទឹក រមែងបង្អុរចុះមកដើម្បីខ្ញុំ ក្នុងទីនេះ សព្វ ៗ ពេល ៗ ខ្ញុំអន្ទោលទៅក្នុងភព កំណត់ដឹងនូវអាសវៈទាំងអស់ ជាអ្នកមិនមានអាសវៈ ដោយការឲ្យនូវសាច់ មានរសឆ្ងាញ់នោះឯង ៗ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃការឲ្យនូវសាច់ មានរសឆ្ងាញ់នោះឯង ៗ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ៗ ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់ដោយលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើហើយ ៗ

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា មធុមំសទាយកោ ថេរោ
ឥមា គាថាយោ អភាសិត្ថាតិ ។

មធុមំសទាយកត្ថេរស្ស អបទានំ សមត្តំ ។

បញ្ចមំ នាគបល្លវកត្ថេរាបទានំ

(៥) នគរេ ពន្ធុមតិយា រាជុយ្យានេ វសាមហំ
មម អស្សមសាមន្តា និសីទិ លោកនាយកោ ។
នាគបល្លវមាទាយ ពុទ្ធស្ស អភិរោបយឹ
បសន្នចិត្តោ សុមនោ សុគតំ អភិវាទយឹ ។
ឯកនវុតេ ឥតោ កប្បេ យំ បល្លវមភិបូជយឹ
ទុគ្គតឹ នាភិជានាមិ ពុទ្ធបូជាយិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យ
ជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បាន
ប្រតិបត្តិហើយ ។

បានឮថា ព្រះមធុមំសទាយកត្ថេរ មានអាយុ បានសម្តែង
នូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ មធុមំសទាយកត្ថេរាបទាន ។

ឆាគបល្ល្រកត្ថេរាបទាន ទី ៥

(៥) ខ្ញុំនៅក្នុងនន្ទារាមរបស់ព្រះរាជា ក្នុងក្រុងពន្ធុមតី
ជាព្រះលោកនាយក គង់ដាតអាស្រមរបស់ខ្ញុំ ។ ខ្ញុំមានចិត្ត
ជ្រះថ្លា មានចិត្តរីករាយ បានយកស្លឹកឈូងទៅបូជាព្រះពុទ្ធ
ហើយថ្វាយបង្គំព្រះសុគត ។ ក្នុងកប្ប ៩១ អំពីកប្ប នេះ
ព្រោះហេតុដែលខ្ញុំ បានបូជាស្លឹក ខ្ញុំមិនដែលស្គាល់ទុគ្គតិ
នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញ
ហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជា
បុគ្គលមិនមានអាសវៈ ដូចដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្ផត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឬភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឆាតបល្លវិកោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ឆាតបល្លវិកត្ថេរស្ស អបទានំ សមត្តំ ។

ធម្ម ឯកទីបិយត្ថេរាបទានំ

(៦) បវិនិ ពុទ្ធម្ហិ សុក្ខតេ សិទ្ធត្ថេ លោកនាយកេ
សនេវមានុសា សព្ពេ ឋ្ហជ្ជន្តិ ទ្ធិបទុត្តមំ ។
អាវេមិ តេ ច ចិត្តកេ សិទ្ធត្ថេ លោកនាយកេ
យថាសកេន ថាមេន ចិតំ ឋ្ហជ្ជន្តិ សត្ថុនោ ។

ឱ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់នៃព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំក៏បានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះនាគបល្លវកត្ថេរ មានអាយុ បានសម្ដែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ នាគបល្លវកត្ថេរាបទាន ។

ឯកទីបិយត្ថេរាបទាន ទី ៦

[៦] កាលព្រះសុគតព្រះនាមសិទ្ធត្ថៈ ជាលោកនាយក ទ្រង់បរិនិព្វានហើយ ពួកមនុស្សទាំងទេវតាទាំងអស់ នាំគ្នាបូជាព្រះពុទ្ធដ៏ឧត្តម ជាងសត្វជើងពីរ ។ ក៏កាលដែលព្រះសិទ្ធត្ថៈ ជាលោកនាយក ដែលគេលើកដាក់លើជើងថ្ករហើយ ពួកមនុស្សព្រមទាំងទេវតា នាំគ្នាបូជាជើងថ្ករ នៃព្រះសាស្ដា តាមសមគួរដល់កំឡាំង នៃសទ្ធារបស់ខ្លួន ។

អាទ្ធរេ ចិតកាសុ ធីបំ ឧជ្ជាលយឺ អហំ
យាវ ឧនេតិ សុរិយោ ធីបំ មេ តាវ បជ្ជលិ ។
តេន ការេន ការេន ទេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវត្តឹសំ អកញ្ចហំ ។
ឥត្ថ មេ សុការ ត្ថ ញ្ញាយ
ធីបសតសហស្ស ញ្ញាយ ។
ឧទយន្តេ សុរិយោ ទេវោ មេ ជលតេ ។

សប្ជ្ជ(១) ។

ឥ ។ ។

ធ ។ ។

ធ ។ ។

ធ ។ ។

ធ ។ ។

---

១ ១. ។

ខ្ញុំបានអុជប្រទីប ក្នុងទីជិតដើមថ្ករ ប្រទីបរបស់ខ្ញុំ ឆេះទៅដរាបព្រះអាទិត្យរះឡើង ។ ខ្ញុំបានលះបង់នូវរាងកាយ ជារបស់មនុស្ស ទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលខ្ញុំធ្វើល្អហើយនោះផង ដោយការតំកល់ចេតនានោះផង ។ វិមានរបស់ខ្ញុំ ដែលបុញ្ញកម្មធ្វើល្អហើយ ក្នុងឋានតាវត្តិង្សនោះ គេរមែងស្គាល់ថា វិមានឈ្មោះឯកទីប ព្រោះមានប្រទីបមួយសែន រុងរឿង ក្នុងវិមានរបស់ខ្ញុំនោះ ។ រាងកាយរបស់ខ្ញុំរមែងរុងរឿងសព្វកាល ដូចព្រះអាទិត្យកាលរះឡើង ពន្លឺសរីរៈ របស់ខ្ញុំ រមែងមានសព្វ ៗ កាល ជាងពន្លឺទាំងឡាយ ។ ខ្ញុំមានភ្នែកមើលឃើញទៅ ខាងក្រៅជញ្ជាំង ខាងក្រៅភ្នំ កន្លងភ្នំ មួយរយយោជន៍ជុំវិញ ។ ខ្ញុំបានត្រេកអរក្នុងទេវលោក អស់ ៧៧ ដង បានសោយរាជ្យ ជាស្តេចទេវតាអស់ ៣១ ដង ។ ខ្ញុំបានជាស្តេចចក្រពត្តិ អស់ ២៨ ដង សោយបទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ។

ផ្ដុំ ឯកទីបិយត្ថេរាបទានំ

ទេវលោកា ចវិត្វាន និព្វត្តឹ មាតុកុច្ឆិយំ
មាតុកុច្ឆិគតស្សាបិ អក្ខិ មេ ន វិនស្សតិ(១) ។
ជាតិយា ចតុវស្សោហំ បព្វជឹ អនគារិយំ
អឌ្ឍមាសេ អសម្បត្តេ អរហត្តំ អបាបុណឹ ។
ទិព្វចក្ខុំ វិសោធេសឹ ភវា សព្វេ សមូហតា
សព្វេ កិលេសា សញ្ឆិន្នា ឯកទីបស្សិទំ ផលំ ។
តិរោកុឌ្ឌំ តិរោសេលំ បព្វតញ្ចាបិ កេវលំ
សមតិក្កម្ម បស្សាមិ ឯកទីបស្សិទំ ផលំ ។
វិសមា មេ សមា ហោន្តិ អន្ធការោ ន វិជ្ជតិ
នាហំ បស្សាមិ តិមិរំ ឯកទីបស្សិទំ ផលំ ។
ចតុន្នវុតេ ឥតោ កប្បេ យំ ទីបមទទឹ តទា
ទុគ្គតឹ នាភិជានាមិ ឯកទីបស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។

---

១ ឱ. ន និមីលតិ ។ ម. ន និមីសតិ ។

កាលខ្ញុំច្យុតចាកទេវលោក មកកើតក្នុងផ្ទៃមាតា សូម្បីកាលខ្ញុំនៅក្នុងផ្ទៃមាតា ភ្នែករបស់ខ្ញុំឥតខ្វះខាតឡើយ ។ ខ្ញុំមានអាយុ ៤ ឆ្នាំ បានចូលទៅកាន់ផ្នួស មិនទាន់បានកន្លះខែ ខ្ញុំក៏បានសម្រេចអរហត្ត ។ ខ្ញុំបានជំរះទិព្វចក្ខុ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ កិលេសទាំងអស់ ខ្ញុំបានផ្តាច់ផ្តិលហើយ នេះជាផលនៃប្រទីបមួយ ។ ខ្ញុំមើលឃើញទៅ ខាងក្រៅជញ្ជាំង ទាំងខាងក្រៅភ្នំ ក្នុងភ្នំទាំងអស់ នេះជាផលនៃប្រទីបមួយ ។ ប្រទេសទាំងឡាយដែលមិនរាបស្មើ ត្រឡប់ទៅជារាបស្មើ សម្រាប់ខ្ញុំ ខ្ញុំមិនមានងងឹត ខ្ញុំមិនដែលឃើញងងឹតអ័ព្ទឡើយ នេះជាផលនៃប្រទីបមួយ ។ ក្នុងកប្បទី ៩៤ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានថ្វាយប្រទីប ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃប្រទីបមួយ ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្ទីង ។

សុត្តន្តបិដកេ ខុទ្ទកនិកាយស្ស អបទានំ

ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្ផត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិ ច អដ្ឋិមេ
ឆឬភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនំ ។
ឥត្តំ សុទំ អាយស្មា ឯកធីបិយោ ថេរោ ឥមា
គាថាយោ អភាសិត្ថាតិ ។

ឯកធីបិយត្ថេរស្ស អបទានំ សមត្តំ ។

សត្តមំ ខុជ្ជុត្តរបុប្ផិយត្ថេរាបទានំ

(៧) ឧតរេ ពន្ធុមតិយា អហោសឹ មាលិកោ ឥធ
ខុជ្ជុត្តរំ ឋ្ឋ យ ិ ត្វាន អកមំ អ ត្ត ភ ណ ិ ។
ភ ក ភ ា ឥ ម្ហ ិ ស ម យ េ ភ ិ ក ្ ខ ុ ស ង ្ ឆ ប ុ ร ក ្ ខ ោ
ម ហ ា ត ា អ ន ុ ភ ា ว េ ន ធ ិ យ ្ យ ា ត ិ ล ោ ก ธ ย ោ ។
ធ ិ ส ្ ว า ธ ล ោ ก ป ช ្ ช ោ ต ํ ว ิ ป ส ฺ ส ี ล ោ ก ต ารณ ํ
ป ุ ป ฺ ผ ํ ป ก ฺ ข ิ ย ฺ ห ฺ ม ฺ ข ุ ช ฺ ช ุ ต ฺ ต ร า พ ุ ท ฺ ธ ส ฺ ส ํ อ ภ ู ช ย ึ ។

ខ ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឯកទីបិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឯកទីបិយត្ថេរាបទាន ។

ឧច្ឆង្គបុប្ផិយត្ថេរាបទាន ទី ៧

(៧) កាលនោះ ខ្ញុំជាអ្នកក្រងផ្កា នៅក្នុងក្រុងពន្ធុមតី ខ្ញុំបានដាក់ផ្កាពេញថ្នក់ ហើយដើរសំដៅផ្សារ ។ សម័យនោះ ព្រះមានព្រះភាគ ជាលោកនាយក មានភិក្ខុសង្ឃចោមរោម កំពុងស្តេចទៅ ដោយអានុភាពដ៏ធំ ។ ខ្ញុំបានឃើញព្រះវិបស្សី ព្រះអង្គបំភ្លឺលោក ទ្រង់ចំឡងសត្វលោក ហើយយកផ្កាអំពីថ្នក់ បូជាព្រះពុទ្ធដ៏ប្រសើរ ។

សត្តមំ ឧជ្ជង្គបុរ្ជ័យត្ថេរបទានំ

ឯកនវុតេ ឥតោ កប្បេ ពុទ្ធសេដ្ឋំ អបូជយឹ

ទុក្ខតំ ឆាកជាតាមិ ពុទ្ធបូជាយិទំ ផលំ ។

តិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា

ឆាគោវ ពន្ធនំ ឆេត្វា វិហរামិ អនាសវោ ។

ស្វាគតំ វតមេ អាសិ មម ពុទ្ធស្ស សន្តិកេ

តិស្សោ វិជ្ជា អនុប្ផត្តា កតំ ពុទ្ធស្ស សាសនំ ។

បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ

ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា ឧជ្ជង្គបុរ្ជ័យោ ថេរោ ឥមា

គាថាយោ អភាសិត្ថាតិ ។

ឧជ្ជង្គបុរ្ជ័យត្ថេរស្ស អបទានំ សមត្តំ ។

ឧច្ឆង្គបុប្ផិយត្ថេរាបទាន ទី ៧

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានបូជាព្រះពុទ្ធដ៏ប្រសើរ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃពុទ្ធបូជា ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់នូវទន្លីង ។ ល ។ ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះឧច្ឆង្គបុប្ផិយត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ ឧច្ឆង្គបុប្ផិយត្ថេរាបទាន ។

អដ្ឋមំ យាគុទាយកត្ថេរាបទានំ

(៨) អតិថី(១) មេ គហេត្វាន អគច្ឆឹ គាមកំ តទា

សម្បុណ្ណនទិកំ ទិស្វា សង្ឃារាមំ ឧបាគមឹ ។
អារញ្ញកា ធុតធរា ឈាយិនោ លូខចីវរា
វិវេកាភិរតា ធីរា សង្ឃារាមេ វសន្តិ តេ ។
គតិ តេសំ ឧបច្ឆិន្នា សុវិមុត្តាន តាទិនំ
បិណ្ឌាយ តេ ន គច្ឆន្តិ ឱរុទ្ធនទិកាយតី(២) ។
បសន្នចិត្តោ សុមនោ វេទជាតោ កតញ្ជលី
តណ្ឌុលំ បគ្គហេត្វាន យាគុទានំ អទាសហំ ។
បចនំ(៣) យាគុំ ទត្វាន បសន្នោ សេហិ បាណិភិ
សកកម្មាភិរទ្ធោហំ តាវត្តិំសំ អគច្ឆហំ ។
មណិមយញ្ច មេ ព្យម្ហំ និព្វត្តំ(៤) តិទសេ គណេ
នារីគណេហិ សំហិតោ(៥) មោទាមិ ព្យម្ហមុត្តមេ ។

---

១ ម. អតីតំ ។ ២ ម. ឱរុទ្ធំ នទិពាយតិ ។ ៣ ឱ. ម. បច្ចនំ ។ ៤ ម. និព្វត្តិ ។
៥ ឱ. សហិតោ ។ ម. មហិតោ ។

យាគុទាយកត្ថេរាបទាន ទី ៨

(៨) កាលនោះ ខ្ញុំនាំក្ងៀរបស់ខ្ញុំ មកកាន់ស្រុកគ្ងប ។ ខ្ញុំបានឃើញសួងមានទឹកពេញត្រៀម ហើយដើរចូលទៅកាន់អាកមរបស់សង្ឆ ។ ភិក្ខុទាំងនោះ ជាអ្នកនៅក្នុងព្រៃ ទ្រ-ទ្រង់ទ្ងវធុតង្គ មានឈាន មានចីវរដ៏សៅហ្មង ត្រេកអរក្នុងទីស្ងាត់ ជាអ្នកប្រាជ្ញ នៅក្នុងអាកមរបស់សង្ឆ ។ ភិក្ខុទាំងនោះ លោកជាអ្នកវ្ងបស្រឡះល្អហើយ ប្រកបដោយគាទិគុណ មានដំណើរដាច់ហើយ ភិក្ខុទាំងនោះមានសួងស្ងុះផ្ងរ ក៏ទានទៅបិណ្ឌបាត ។ ខ្ញុំមានចិត្តជ្រះថ្ងា មានចិត្តរីករាយ មានចិត្តត្រេកអរ ហើយធ្ងើអញ្ជលី យកអង្ករធ្ងើបបរ ប្រគេនយាគុទាន ។ ខ្ញុំមានចិត្តជ្រះថ្ងា ប្រគេនបបរ ដែលចំអិនហើយ ដោយដៃរបស់ខ្ងួន ប្រារព្ធកម្មរបស់ខ្ងួន ចូលទៅកើតឯឋានតាវត្តឹង្ឆ ។ វិមានជាវិការៈនៃកែវមណី កើតសម្រាប់ខ្ញុំ ក្នុងពួកទេវតាឋានតាវត្តិង្ឆ ខ្ញុំប្រកបដោយពួកនារី ត្រេកអរ ក្នុងវិមានដ៏ប្រសើរ ។

អដ្ឋមំ យាគុទាយកត្ថេរាបទានំ

តេត្តឹសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជមការយឹ
តឹសក្ខត្តុំ ចក្កវត្តិ មហារជ្ជមការយឹ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
ទេវលោកេ មនុស្សេ វា អនុភោត្វា យសំ អហំ ។
បច្ឆិមេ ភវសម្បត្តេ បព្វជឹ អនគារិយំ
សហ ឱរោបិតេ កេសេ សព្វសម្បត្តិវិជ្ជហំ ។
ខយតោ វយតោ ចាបិ សម្មសន្តោ កលេវរំ
បុរេ សិក្ខាបទានេន អរហត្តំ អបាបុណឹ ។
សុទិន្នំ មេ ទានវរំ វាណិជំ សុប្បយោជិតំ(១)
តេនេវ យាគុទានេន បត្តោម្ហិ អចលំ បទំ ។
សោកំ បរិទ្ទវំ ព្យាធឹ ទរថំ ចិត្តតាបនំ
នាភិជានាមិ ឧប្បន្នំ យាគុទានស្សិទំ ផលំ ។

១ ម. សម្បយោជិតំ ។

ខ្ញុំបានជាព្រះឥន្ទ្រ សោយកាជ្ជជាស្តេចនៃទេវតា អស់ ៣៣ ដង បានសោយកាជ្ជដ៏ធំ ជាស្តេចចក្រពត្តិ អស់ ៣០ ដង បានសោយប្រទេសកាជ្ជ ដ៏ធំទូលាយ ១០ជាតិមិនអស់ ខ្ញុំសោយនូវយស ក្នុងទេវលោកនិងមនុស្សលោក ។ ក្នុងកាលដែលដល់នូវកតជាទីបំផុត ខ្ញុំបានលះបង់សម្បត្តិទាំងអស់ ព្រមទាំងសក់ដែលកោរកាត់ រួចហើយចូលទៅកាន់ផ្នួស ។ ម្យ៉ាងទៀត កាលខ្ញុំពិចារណានូវសាកសពដោយកិរិយាអស់ទៅនិងការសូន្យទៅ ក៏បានសម្រេចព្រះអរហត្ត ដោយការបំពេញនូវសិក្ខា ក្នុងកាលមុន ។ ទានដ៏ប្រសើរ ខ្ញុំបានឲ្យហើយដោយប្រពៃ ទានកើតឡើងដោយដៃ ខ្ញុំបានប្រកបប្រពៃហើយ ខ្ញុំជាបុគ្គលបានដល់នូវអចលបទ គឺនិព្វានដោយយាគុទាននោះឯង ។ ខ្ញុំមិនដែលស្គាល់សេចក្តីសោក សេចក្តីខ្សឹកខ្សួល ការឈឺក្ដាត់ ក្រវល់ក្រវាយនិងសេចក្តីក្តៅក្រហាយចិត្ត ដែលកើតឡើយ នេះជាផលនៃយាគុទាន ។

យាគុំ សង្ឃស្ស ទត្វាន បុញ្ញក្ខេត្តេ អនុត្តរេ

បញ្ចានិសំសេ អនុភោមិ អហោ យាគុសុយិដ្ឋតា

អព្យាធិតា រូបវតា ខិប្បំ ធម្មំ និពុជ្ឈិតា(១)

លាភិតា អន្នបានស្ស អាយុបញ្ចមកំ មម ។

យោ កោចិ វេទំ ជនយំ សង្ឃេ យាគុំ ទទេយ្យ សោ

ឥមានិ បញ្ច ឋានានិ បដិគ្គណ្ហេយ្យ បណ្ឌិតោ ។

ករណីយំ កតំ សព្វំ ភវា ឧគ្ឃាដិតា មយា

សព្វាសវា បរិក្ខីណា(២) នត្ថិ ទានិ បុនព្ភវោ ។

សោ អហំ វិចរិស្សាមិ គាមា គាមំ បុរា បុរំ

នមស្សមានោ សម្ពុទ្ធំ ធម្មស្ស ច សុធម្មតំ ។

---

១ ឱ. ម. ខិប្បំ ធម្មនិសន្តិតា ។ ២ ឱ. ម. សព្វាសវបរិក្ខីណោ ។

ខ្ញុំបានប្រគេនបបរដល់ព្រះភិក្ខុសង្ឃ ជាបុញ្ញក្ខេត្តដ៏ប្រសើររួចហើយ ក៏បានទទួលអានិសង្ស ៥ ប្រការ ម្នាលភិក្ខុ ! កាលនៃបបរខ្ញុំបានបួជាស្រួលហើយ ។ (អានិសង្ស ៥ ប្រការនោះ គឺ) ភាពជាអ្នកមិនមានជម្ងឺដម្កាត់ ១ ភាពជាអ្នកមានរូបល្អ ១ ភាពជាអ្នកត្រាស់ដឹងនូវធម៌ឆាប់ ១ ភាពជាអ្នកបានបាយនិងទឹកជាប្រក្រតី ១ ខ្ញុំមានអាយុវែង ជាគំរប់៥ ។ បុគ្គលណាមួយកាលធ្វើសេចក្តីត្រេកអរឲ្យកើត គប្បីប្រគេនបបរចំពោះព្រះសង្ឃ បុគ្គលនោះឈ្មោះថាបណ្ឌិត តែងទទួលឋានៈ ៥ ប្រការនេះឯង ។ករណីយកិច្ចទាំងអស់ ខ្ញុំបានធ្វើរួចហើយ ភពទាំងឡាយ ខ្ញុំបានគាស់រំលើងចោលហើយ អាសវៈទាំងពួងរបស់ខ្ញុំ អស់រលីងហើយ ឥឡូវនេះ ភពថ្មីទៀតមិនមានទេ ។ ខ្ញុំនោះតែងដើរទៅកាន់ស្រុកតូច-ធំ និងបុរីតូច-ធំ តែងថ្វាយបង្គំនូវព្រះសម្ពុទ្ធ និងព្រះធម៌ជាសភាវៈដ៏ល្អ ។

អដ្ឋមំ យាគុទាយកត្ថេរាបទានំ

តឹសកប្បសហស្សម្ហិ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ យាគុទានស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា យាគុទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

យាគុទាយកត្ថេរស្ស អបទានំ សមត្តំ ។

ក្នុងកប្ប៧ ៣០ ពាន់ អំពីកប្ប១នេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំពុំដែលស្គាល់ទុគ្គតិ នេះជាផលនៃយាគុទាន ។ កិលេសទាំងឡាយ ខ្ញុំបានដុតបំផ្លាញហើយ ភពទាំងអស់ ខ្ញុំបានគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរ កាត់ផ្តាច់ទ្រូងទ្ទីង ។ ឆ ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អ ! ១ ២ ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចស្រេចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះយាគុកាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ យាគុកាយកត្ថេរបទាន ។

នវមំ បត្តោទកទាយកត្ថេរាបទានំ

(៩) វនចារី បុរេ អាសឹ សតតំ វនកម្មិកោ
បត្តោទកំ គហេត្វាន កម្មន្តំ អគមាសហំ ។
តត្ថទ្ទសាសឹ សម្ពុទ្ធំ សយម្ភុំ អបរាជិតំ
វនា បិណ្ឌាយ និក្ខន្តំ ទិស្វា ចិត្តំ បសាទយឹ ។
បរកម្មាយនេ(១) យុត្តោ បុញ្ញុ មេ ន វិជ្ជតិ
អយំ បត្តោទកោ អត្ថិ ភោជយិស្សាមិមំ មុនឹ ។
បត្តោទកំ គហេត្វាន សយម្ភុស្ស អទាសហំ
មម និជ្ឈាយមានស្ស បរិភុញ្ជិ មហាមុនិ(២) ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។

---

១ ម. វិយេកម្មាយនេ ។ ២ ឱ ម. ឥទា មុនិ ។

បណ្ណោទនទាយកត្ថេរាបទាន ទី ៩

(៩) កាលពីកន្លងមុន ខ្ញុំបានកើតជាជ្មើរព្រៃ ប្រកបការក្នុងព្រៃរឿយ ។ បានយកបាយដែលចំអិនដោយអង្ករចំនួនមួយនាឡិ ហើយដើរទៅធ្វើការងារ ។ ខ្ញុំបានឃើញព្រះសម្ពុទ្ធជាព្រះសយម្ភូ ទ្រង់ឈ្នះមារ ព្រះអង្គកំពុងស្តេចចេញពីព្រៃទៅបិណ្ឌបាតក្នុងទីនោះ លុះខ្ញុំបានឃើញហើយ ក៏ញុំងចិត្តឲ្យជ្រះថ្លាថា អញរវល់តែប្រកបក្នុងការងារ ឲ្យអ្នកដទៃចំណែកបុណ្យរបស់អញ មិនមាន ឥឡូវនេះ បាយដែលចំអិនដោយអង្ករមួយនាឡិនេះមាន អញនឹងនិមន្តព្រះមុនីនេះឲ្យឆាន់បាយនេះ ។ ខ្ញុំយកបាយដែលចំចិនដោយអង្ករមួយនាឡិ ថ្វាយព្រះសយម្ភូ កាលខ្ញុំកំពុងតែសំឡឹងមើល ព្រះមហាមុនីទ្រង់សោយ ។ ខ្ញុំលះបង់ពន្ធកាយ ជារបស់មនុស្សហើយ បានទៅកើតឯឋានតាវត្តិង្ស ដោយកម្មដែលធ្វើល្អហើយនោះផង ដោយការតំកល់ចេតនានោះផង ។

ធម៌ បត្តោទនទាយកត្ថេរាបទានំ

ឆត្តឹសក្ខត្តុំ(១) ទេវិន្ទោ   ទេវរជ្ជមការយឹ
តេត្តឹសក្ខត្តុំ រាជា ច   ចក្កវត្តិ អហោសហំ(២) ។
បទេសរជ្ជំ វិបុលំ   គណនាតោ អសង្ខិយំ
សុខិតោ យសវា ហោមិ   បត្តោទនស្សិទំ ផលំ ។
ភវាភវេ សំសរន្តោ   លភាមិ អមិតំ ធនំ
ភោគេ មេ ឩនតា នត្ថិ   បត្តោទនស្សិទំ ផលំ ។
នទីសោតប្បដិភាគា   ភោគា និព្ពត្តរេ មម
បរិមេតុំ ន សក្កោមិ   បត្តោទនស្សិទំ ផលំ ។
ឥមំ ខាទ ឥមំ ភុញ្ជ   ឥមម្ហិ សយនេ សយ
តេនាហំ សុខិតោ ហោមិ   បត្តោទនស្សិទំ ផលំ ។

---

១ ឧ. ម. ឆត្តឹសក្ខត្តុំ ។

ខ្ញុំបានជាព្រះឥន្ទ្រ សោយរាជ្យជាស្ដេចទេវតា អស់ ៣២ ដង បានជាស្ដេចចក្រពត្តិ អស់ ៣៣ ដង ។ បានសោយរាជ្យជាក្សត្រប្រទេសរាជ្យ ដ៏ធំទូលាយ រាប់ជាតិមិនអស់ ខ្ញុំជាអ្នកដល់សេចក្ដីសុខ មានយស នេះជាផលនៃបាយដែលចំអិនដោយអង្ក្រមួយនាឡ្ស ។ ខ្ញុំកាលអន្ទោលទៅមកក្នុងភពតូចនិងភពធំ រមែងបានទ្រព្យរាប់មិនអស់ ខ្ញុំមិនដែលមានការខ្វះខាតកោគៈទេ នេះជាផល នៃបាយដែលចំអិនដោយអង្ក្រមួយនាឡ្ស ។ កោគៈចាំងឆ្ងាយដែលមានចំណែកប្រៀបដូចខ្សែទឹកទន្ទ្ រមែងកើតសម្រាប់ខ្ញុំ ខ្ញុំមិនអាចរាប់កោគៈចាំងនោះឲ្យសព្វគ្រប់បានទេ នេះជាផលនៃបាយដែលចំអិនដោយអង្ក្រមួយនាឡ្ស ។ (ពួកជនតែងពោលថា) អ្នកចូរចំពាស្ទ្ចំណីនេះ ចូរបរិភោគអាហារនេះ ចូរដេកលើដំណេកនេះ ព្រោះហេតុនេះ ខ្ញុំជាបុគ្គលបានសុខស្រួល នេះជាផលនៃបាយ ដែលចំអិនដោយអង្ក្រមួយនាឡ្ស ។

ឯកនវុតេ(១) ឥតោ កប្បេ យំ ទានមទទឹ តទា
ទុគ្គតឹ នាភិជានាមិ បត្តោទនស្សិទំ ផលំ ។
កិលេសា ឈាបិតា មយ្ហំ ភវា សព្វេ សមូហតា
នាគោវ ពន្ធនំ ឆេត្វា វិហរាមិ អនាសវោ ។
ស្វាគតំ វត មេ អាសិ មម ពុទ្ធស្ស សន្តិកេ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនំ ។
បដិសម្ភិទា ចតស្សោ វិមោក្ខាបិច អដ្ឋិមេ
ឆឡភិញ្ញា សច្ឆិកតា កតំ ពុទ្ធស្ស សាសនន្តិ ។

ឥត្ថំ សុទំ អាយស្មា បត្តោទនទាយកោ ថេរោ ឥមា គាថាយោ អភាសិត្ថាតិ ។

បត្តោទនទាយកត្ថេរស្ស អបទានំ សមត្តំ ។

---

១ ឱ. ម. ចតុន្នវុតេ ។

ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រោះហេតុដែលខ្ញុំបានឲ្យទាន ក្នុងកាលនោះ ខ្ញុំមិនដែលស្គាល់ទុគ្គតិ នេះជាផលនៃបាយ ដែលបំអិនដោយអង្ករមួយនាឡិ ។ កិលេសទាំងឡាយ ខ្ញុំដុតបំផ្លាញចោលហើយ ភពទាំងអស់ ខ្ញុំគាស់រំលើងចោលហើយ ខ្ញុំជាបុគ្គលមិនមានអាសវៈ ដូចជាដំរីដ៏ប្រសើរកាត់ផ្តាច់នូវទន្លីង ។ ឱ! ដំណើរដែលខ្ញុំមក ក្នុងសំណាក់ព្រះពុទ្ធរបស់ខ្ញុំ ជាដំណើរល្អហ្ន៎ វិជ្ជា ៣ ខ្ញុំបានដល់តាមលំដាប់ហើយ សាសនា របស់ព្រះពុទ្ធ ខ្ញុំបានធ្វើរួចហើយ ។ បដិសម្ភិទា ៤ វិមោក្ខ ៨ និងអភិញ្ញា ៦ នេះ ខ្ញុំបានធ្វើឲ្យជាក់ច្បាស់ហើយ ទាំងសាសនា របស់ព្រះពុទ្ធ ខ្ញុំក៏បានប្រតិបត្តិហើយ ។

បានឮថា ព្រះបត្តោទនទាយកត្ថេរ មានអាយុ បានសម្តែងនូវគាថាទាំងនេះ ដោយប្រការដូច្នេះ ។

ចប់ បត្តោទនទាយកត្ថេរាបទាន ។

ទសមំ មញ្ចទាយកត្ថេរាបទានំ

(១០) បរិនិព្វុតេ ការុណិកេ សិទ្ធត្ថេ លោកនាយកេ
វិត្ថារិកេ ពាវចនេ ទេវមនុស្សសក្កតេ ។
ចណ្ឌាលោ អាសហំ តត្ថ អាសន្ទិបីឋការកោ
តេន កម្មេន ជីវាមិ តេន បោសេមិ ទារកេ ។
អាសន្ទឹ សុកតំ កត្វា បសន្នោ សេហិ បាណិភិ
សយមេវ ឧបគន្ត្វា ភិក្ខុសង្ឃស្សទាសហំ ។
តេន កម្មេន សុកតេន ចេតនាបណិធីហិ ច
ជហិត្វា មានុសំ ទេហំ តាវតឹសំ អគញ្ឆហំ ។
ទេវលោកំ គតោ សន្តោ មោទាមិ តិទសេ គណេ
សយនានិ មហគ្ឃានិ និព្វត្តន្តិ យទិច្ឆកំ(១) ។

---
១ ឱ. ម. យទិច្ឆកំ ។

មញ្ជូទាយកត្ថេរាបទាន ទី ១០

(១០) កាលព្រះលោកនាយក ព្រះនាមសិទ្ធត្ថ: ប្រ-
ជុបដោយសេចក្តីករុណា ទ្រង់ចូលនិព្វានហើយ កាលសា-
សនា កំពុងផ្សាយចេញទៅ មានពួកទេវតានិងមនុស្សធ្វើ
សក្ការ:ហើយ ។ ខ្ញុំកើតជាមនុស្សបណ្ឌិត អ្នកធ្វើតាំង
ឈ្មោះអាសន្ទិ (តាំងមានជ្រុង ៤ ស្មើ) ក្នុងទីនោះ ខ្ញុំ
រស់នៅដោយការងារនោះ ចាំងបានចិញ្ចឹមជីវិតនិងប្រពន្ធ
ដោយការងារនោះដែរ ។ ខ្ញុំមានចិត្តជ្រះថ្លា បានធ្វើតាំង
ឈ្មោះអាសន្ទិ ចិចត្រយ៉ាងល្អ ដោយដៃរបស់ខ្លួន ហើយនាំ
ចូលទៅប្រគេនព្រះកិកុសង្ឆ ដោយខ្លួនឯង ។ ខ្ញុំលះបង់
ពន្ធកាយ ជារបស់មនុស្សហើយ បានទៅកើតឯឋានតាវ-
ត្តិង្ស ដោយកម្មដែលខ្លួនធ្វើល្អហើយនោះផង ដោយការ
តំកល់ចេតនានោះផង ។ ខ្ញុំកាលទៅកាន់ទេវលោក រមែង
រីកពយ ក្នុងពួកទេវតា នៅឋានតាវត្តិង្ស ទីសម្រាប់ដេក
មានថ្ងៃច្រើន ក៏កើតឡើងតាមសេចក្តីប្រាថ្នា (របស់ខ្ញុំ) ។

បញ្ញាសក្ខត្តុំ ទេវិន្ទោ ទេវរជ្ជមការយិំ
អសីតិក្ខត្តុំ រាជា ច ចក្កវត្តិ អហោសហំ ។
បទេសរជ្ជំ វិបុលំ គណនាតោ អសង្ខិយំ
